# បេឡាជាតិរបបសន្តិសុខសង្គម
# National Social Security Fund

ព្រឹត្តិបត្រព័ត៌មាន

## ប.ស.ស ឆ្នាំទី០៨ លេខ២៣ ឆ្នាំ២០១៨



**ធានាសន្តិសុខប្រាក់ចំណូល**

**រួមចំណែកកាត់បន្ថយភាពក្រីក្រ**

**លើកកម្ពស់សិរីភាពសង្គម**

**ទំនាក់ទំនងបន្ទាន់**

**១២៨៦**

**២៤ម៉ោង/៧ថ្ងៃ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន
មន្ទីរព័ត៌មានរាជធានីភ្នំពេញ
លេខ..៣៣៤../ព.ពមរ
/១៧

ភ្នំពេញ,ថ្ងៃទី..០៤..ខែ..ធ្នូ........ឆ្នាំ២០១៧

# លិខិតអនុញ្ញាត

## ប្រធានមន្ទីរព័ត៌មានរាជធានីភ្នំពេញ

យោង: -ប្រកាសលេខ១០៨ព.ម.ប្រ.ក ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៤ របស់ក្រសួងព័ត៌មាន។

-លិខិតអនុញ្ញាតលេខ០០៤/១៧ល.អ.ព.ម.រ ចុះថ្ងៃទី ០៣ ខែមករា ឆ្នាំ ២០១៧ របស់មន្ទីរព័ត៌មានរាជធានីភ្នំពេញ។

-ពាក្យស្នើសុំអនុញ្ញាតបន្តអាជ្ញាប័ណ្ណបោះពុម្ពផ្សាយព្រឹត្តិបត្រ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៧ របស់លោក **ជាវ ប៊ុនរិទ្ធ** ចាងហ្វាងការផ្សាយព្រឹត្តិបត្រ **បេឡាជាតិរបបសន្តិសុខសង្គម**។

តាមសេចក្តីយោងខាងលើនេះ មន្ទីរព័ត៌មានរាជធានីភ្នំពេញ សូមជម្រាបជូនមកលោក **ជាវ ប៊ុនរិទ្ធ** ចាងហ្វាងការផ្សាយព្រឹត្តិបត្រ **បេឡាជាតិរបបសន្តិសុខសង្គម** ជ្រាបថា មន្ទីរព័ត៌មានរាជធានីភ្នំពេញ អនុញ្ញាតឲ្យលោកចាងហ្វាងបន្តដំណើរការបោះពុម្ពផ្សាយចាងហ្វាងការផ្សាយព្រឹត្តិបត្រ **បេឡាជាតិរបបសន្តិសុខសង្គម** ដែលមានទីស្នាក់ការនៅអាគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ បន្តពីលិខិតអនុញ្ញាតលេខ០០៤/១៧ ល.អ.ព.ម.រ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៧ របស់មន្ទីរព័ត៌មានរាជធានីភ្នំពេញ។

ក្នុងដំណើរការបោះពុម្ពផ្សាយ លោកចាងហ្វាងត្រូវគោរពអនុវត្តឲ្យបានត្រឹមត្រូវតាមខ្លឹមសារប្រកាសរបស់ក្រសួងព័ត៌មាន ដូចយោងខាងលើ។

ករណីប្រព្រឹត្តល្មើស នឹងប្រកាសអនុញ្ញាតរបស់ក្រសួងព័ត៌មាន សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន។

លិខិតអនុញ្ញាតនេះ មានសុពលភាពរយៈពេល ០១ (មួយឆ្នាំ) គិតពីថ្ងៃចុះហត្ថលេខាតទៅ។

**ប្រធានមន្ទីរ**

**ឃុត_សំខាន់**

***កន្លែងទទួល***
- ក្រសួងព័ត៌មាន
- អគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍
- សាលារាជធានីភ្នំពេញ
  (ដើម្បីជ្រាបជាព័ត៌មាន)
- កងរាជអាវុធហត្ថរាជធានីភ្នំពេញ
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- ឯកសារ-កាលប្បវត្តិ





# មាតិកាព្រឹត្តិបត្រព័ត៌មាន ប.ស.ស


| ល.រ | ខ្លឹមសារអត្ថបទ | ទំព័រ |
|---|---|---|
| ០១ | សម្ដេចតេជោនាយករដ្ឋមន្ត្រី ថ្លែងថា នៅឆ្នាំ២០១៩ ប្រាក់ឈ្នួលអប្បបរមា របស់កម្មករ-កម្មការិនី នឹងឡើងខ្ពស់...... | ០១ |
| ០២ | សិក្ខាសាលាពិគ្រោះយោបល់ស្ដីពី សេចក្ដីព្រាងច្បាប់របបសន្តិសុខសង្គម | ០៣ |
| ០៣ | សម្រស់ឯកវាយនភណ្ឌ ប្រចាំឆ្នាំ២០១៨ ទទួលបានជោគជ័យ និងមានការគាំទ្រយ៉ាងពេញទំហឹងពីសាធារណជន...... | ០៥ |
| ០៤ | កិច្ចប្រជុំអន្តរក្រសួង លើសេចក្ដីព្រាងច្បាប់ស្ដីពីរបបសន្តិសុខសង្គម | ០៧ |
| ០៥ | ពិធីចែកប័ណ្ណបើកបរ ដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិតនៅរោងចក្រ... | ០៩ |
| ០៦ | កម្មករនិយោជិតនៅពេលចាស់ជរាអាចចិញ្ចឹមខ្លួនឯងបាននៅពេលច្បាប់ស្ដីពីរបបសន្តិសុខសង្គមថ្មី ដាក់ឱ្យអនុវត្ត | ១១ |
| ០៧ | ពិធីប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយ នៃការអនុវត្តរបបសន្តិសុខសង្គម ដល់និយោជិត ម្ចាស់ សហគ្រាស គ្រឹះស្ថាន នៅខេត្តកំពង់ឆ្នាំង | ១២ |
| ០៨ | គ្មានការរើសអើងណាមួយ ក្នុងការទៅទទួលសេវាសុខភាពតាមរយៈប័ណ្ណ ប.ស.ស នៅគ្រប់មន្ទីរពេទ្យជាដៃគូរបស់ ប.ស.ស | ១៤ |
| ០៩ | គិតត្រឹមថ្ងៃទី០១ ខែ មករា ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ រាជរដ្ឋាភិបាល បានផ្ដល់ថវិកាជាង ៩ពាន់រៀល ជូនកម្មការិនី....... | ១៥ |
| ១០ | បេឡាជាតិរបបសន្តិសុខសង្គម ប.ស.ស បានបញ្ជូនមន្ត្រីជំនាញចូលរួមសិក្ខាសាលាស្ដីពីគោលនយោបាយហិរញ្ញប្បទានសុខាភិបាល | ១៦ |
| ១១ | ដំណើរទស្សនៈកិច្ចសិក្សាផ្លាស់ប្ដូរយោបល់ និងដកស្រង់បទពិសោធន៍នៅប្រទេសថៃ | ១៧ |
| ១២ | កិច្ចប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយអភិវឌ្ឍន៍ វិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាសង្គ្រោះបឋម | ១៩ |
| ១៣ | ប.ស.ស សហការជាមួយក្រសួងមហាផ្ទៃផ្សព្វផ្សាយយន្តការផ្ដល់អត្តសញ្ញាណប័ណ្ណដល់បងប្អូនកម្មករនិយោជិត | ២០ |








| | | |
|---|---|---|
| ១៤ | ប.ស.ស សហការជាមួយគ្រូពេទ្យ TYDA ចុះពិនិត្យព្យាបាលជម្ងឺជូនបងប្អូន កម្មករនិយោជិតនៅក្នុងសង្កាត់ទឹកថ្លា | ២១ |
| ១៥ | មន្ត្រី ប.ស.ស សាខាខេត្តប៉ៃលិន ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ដល់កម្មករនិយោជិត នៅក្រុមហ៊ុន វិចតូរីយ៉ាវ៉ាយអ៊ីន | ២២ |
| ១៦ | សកម្មភាពក្រុមការងារ ប.ស.ស ចុះប្រគល់សម្ភារៈអវយវៈសិប្បនិមិត្ត និងធ្វើបច្ចុប្បន្នភាពជូនសមាជិក ប.ស.ស | ២៣ |
| ១៧ | ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកចុះបណ្តុះបណ្តាលច្បាប់ចរាចរណ៍ផ្លូវគោកដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិត | ២៥ |
| ១៨ | សកម្មភាពក្រុមការងារចុះកំណត់អត្តសញ្ញាណកម្មករនិយោជិត | ៣០ |
| ១៩ | សកម្មភាពក្រុមការងារតាមបណ្តាខេត្ត ចុះបំពេញឯកសារ និងផ្តល់ថវិកាជូនស្រ្តីសម្រាលកូន | ៣២ |
| ២០ | កម្មករនិយោជិត ២រូប បានស្លាប់ និងម្នាក់រងរបួសធ្ងន់ក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ នៅខេត្តព្រះសីហនុ | ៣៤ |
| ២១ | បណ្តាំក្រមង៉ុយ | ៣៥ |
| ២២ | វិធីថែសម្រស់ ១០យ៉ាង ជាមួយនឹងក្រូចឆ្មារ | ៣៦ |









# រចនាសម្ព័ន្ធព្រឹត្តិបត្រ

## ឯកឧត្តម អ៊ុក សមវិទ្យា
## នាយក ប.ស.ស

| | |
|---|---|
| ចាងហ្វាង | ឯកឧត្តម ជាវ ប៊ុនរិទ្ធ |
| និពន្ធនាយក | លោក ហែម សុគន្ធារិន |
| និពន្ធនាយករង | លោក នៅ សុមនា |
| លេខានិពន្ធ | លោក នាង ជូ |
| | លោក យន គន្ធា |
| | លោក លីម តក់ |
| ផ្នែកការីកុំព្យូទ័រ | លោក ពៅ សុវណ្ណារ៉ា |
| | លោក យង់ សុខន |
| | លោក ប៊ុត ស៊ីម |

# អង្គការលេខរបស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)



# សម្តេចតេជោនាយករដ្ឋមន្ត្រី ថ្លែងថា នៅឆ្នាំ២០១៩ ប្រាក់ឈ្នួលអប្បបរមា របស់កម្មករ-កម្មការិនី នឹងឡើងខ្ពស់ជាង ១៧០ ដុល្លារអាមេរិក



**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខដឹកនាំនៃរាជរដ្ឋាភិបាលកម្ពុជា បានថ្លែងថានៅឆ្នាំ ២០១៩ ខាងមុខ ប្រាក់ឈ្នួលអប្បបរមារបស់កម្មករកម្មការិនីនឹងឡើងខ្ពស់ជាង ១៧០ដុល្លារអាមេរិក។ **សម្តេច** បញ្ជាក់ផងដែរថា រាជរដ្ឋាភិបាលនឹងខិតខំកាត់បន្ថយនូវការចំណាយផ្សេងៗ របស់រោងចក្រ ដើម្បីបង្វែរប្រាក់ទាំងនោះមកដំឡើងប្រាក់ឈ្នួលសម្រាប់កម្មករនិយោជិត។

**សម្តេចតេជោ ហ៊ុន សែន** បានថ្លែងបែបនេះកាលពីព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ នេះ នៅក្នុងពិធីជួបសំណេះសំណាលជាមួយកម្មករកម្មការិនីប្រមាណជាង ១,៧ ម៉ឺននាក់ មកពីរោងចក្រ សហគ្រាស ចំនួន១៣ ក្នុងខេត្តតាកែវ។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** ក៏បានអបអរសាទរចំពោះការទទួលបានប្រាក់ឈ្នួលអប្បបរមា ១៧០ដុល្លារ ក្នុងឆ្នាំ២០១៨ ហើយសង្ឃឹមថា ប្រាក់ឈ្នួលនឹងបន្តកើនឡើង នៅក្នុងឆ្នាំ២០១៩ខាងមុខ។ សម្តេចបានបញ្ជាក់ផងដែរថាប្រាក់ឈ្នួលនៅប្រទេសមួយចំនួនទាបជាងកម្ពុជា ដូចនេះត្រូវខិតខំថែរក្សារោងចក្រដែលយើងមាននេះ។

**សម្តេច** ថ្លែងបន្តថាប្រាក់ឈ្នួលអប្បបរមានឹងកើនខ្ពស់ជាង ១៧០ដុល្លារ នេះគឺត្រូវចរចាគ្នាដើម្បីបង្កើនប្រាក់ នៅពេលនោះរាជរដ្ឋាភិបាលក៏កំពុងរកគ្រប់វិធីទាំងអស់ដើម្បីធ្វើឱ្យការចំណាយរបស់ម្ចាស់រោងចក្រ កាន់តែចំណាយតិច ដើម្បីឱ្យម្ចាស់រោងចក្រនោះ ប្រើប្រាស់នូវប្រាក់ចំណេញដើម្បីបង្កើនប្រាក់បៀវត្សចំពោះកម្មករនិយោជិត។

រាជរដ្ឋាភិបាល ក៏បានកំពុងគិតគូរពីថ្លៃអគ្គិសនីសម្រាប់វិស័យឧស្សាហកម្ម ដើម្បីធ្វើយ៉ាងណាឱ្យថ្លៃប្រើប្រាស់អគ្គិសនីរបស់យើងមានតម្លៃថោកដែលអាចធ្វើឱ្យអគ្គិសនីក៏អាចរស់រានបាន និងផ្នែកឧស្សាហកម្មក៏អាចរស់រានបានផងដែរ។



ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលក៏បានគិតគូរពីបញ្ហាផ្សេងៗដទៃទៀត រាប់ទាំងការសម្រួលទៅលើបញ្ហាការដឹកជញ្ជូនសម្រួលទៅលើបញ្ហាការធ្វើពាណិជ្ជកម្មជាដើម ដើម្បីកាត់បន្ថយនូវការចំណាយថ្លៃដើមទៅលើការផលិត ហើយផលចំណេញនោះ ត្រូវបានផ្តល់សម្រាប់ឱ្យកម្មករកម្មការិនីផងដែរ។



ប្រមុខរាជរដ្ឋាភិបាលកម្ពុជាក៏បានគិតគូរបន្ថែមអំពីការកាត់បន្ថយការចំណាយរបស់កម្មករ និងការយកចិត្តទុកដាក់ខ្ពស់ទៅលើបញ្ហាសុខមាលភាព។ **សម្តេច** ក៏បានលើកឡើងផងដែរថា នៅពេលដែលក្មួយៗទទួលបានប្រាក់ឈ្នួលកាន់តែខ្ពស់ រីឯការចំណាយក៏កាន់តែតិចតាមរយៈកម្មវិធីគាំពារសង្គម ឬហៅថាសំណាញ់សុវត្ថិភាពសង្គមដែលរាជរដ្ឋាភិបាលបានផ្តល់ឱ្យកម្មករកម្មការិនីទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធទៅទទួលការពិនិត្យព្យាបាល ជំងឺដោយឥតគិតថ្លៃនៅគ្រប់មន្ទីរពេទ្យរបស់រដ្ឋទាំងអស់។



ចំណែកកម្មករកម្មការិនី នៅក្នុងរាជធានីភ្នំពេញទាំងអស់បានទទួលនូវសេវារថយន្តក្រុង ដោយឥតគិតថ្លៃផងដែរ។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក៏បានលើកឡើងផងដែរថា នៅពាក់កណ្តាលឆ្នាំ ២០១៩ នេះយើងបានសិក្សា ហើយប្រកាសចេញជាក្របខណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិ-បាលនិងមានការអនុវត្តចំពោះស្ត្រីក្រីក្រដែលមានផ្ទៃពោះ និងឆ្លងទន្លេ ដោយទទួលបានថវិកាពីរាជរដ្ឋាភិបាលរហូតដល់ ៧៦ម៉ឺនរៀល វាច្រើនជាងកម្មការិនីដែលបានតែ ៤០ម៉ឺនរៀល ៧៦ម៉ឺនរៀល វាច្រើនជាងកម្មការិនី ដែលបានតែ ៤០ម៉ឺនរៀល និងសុំអធ្យាស្រ័យចំពោះបងប្អូនដែលជាស្ត្រីនៅទូទាំងប្រទេស ដោយថវិកាមិនអាចផ្តល់ឱ្យបានគ្រប់គ្នាទេ ព្រោះនេះគឺជាសមធម៌សម្រាប់អ្នកក្រីក្រដែលរាជរដ្ឋាភិបាលជួយ៕



# សិក្ខាសាលាពិគ្រោះយោបល់ស្តីពីសេចក្តីព្រាងច្បាប់របបសន្តិសុខសង្គម




*គណៈអធិបតីចូលរួមក្នុងអង្គសិក្ខាសាលា*

**ភ្នំពេញ៖** ថ្ងៃព្រហស្បតិ៍ ២រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម នៅភោជនីយដ្ឋានទន្លេបាសាក់២។

សិក្ខាសាលាពិគ្រោះយោបល់នេះ ប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំក្រសួង សមាជិកក្រុមប្រឹក្សាភិបាលនៃ ប.ស.ស តំណាងក្រសួង ស្ថាប័ន អង្គភាព និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា សរុបប្រមាណជាង ២០០នាក់។









សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងពិគ្រោះយោបល់ និងប្រមូលខ្លឹមសារឱ្យបានគ្រប់ជ្រុងជ្រោយ ក្នុងន័យបំពេញបន្ថែមចំណុចណាមួយ នៃសេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គមឱ្យស្របទៅតាមស្ថានភាពសង្គម និងសេដ្ឋកិច្ចដែលកំពុងអភិវឌ្ឍន៍ឆ្ពោះទៅមុខប្រកបដោយស្ថិរភាព ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិត **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចកម្ពុជា។



ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី ថ្លែងពីសេចក្តីព្រាងច្បាប់ស្តីពី របបសន្តិសុខសង្គម

**ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានលើកឡើងថា សិក្ខាសាលានេះថា ដោយអនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ ហ៊ុន សែន** និងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំសេចក្តីព្រាងច្បាប់នេះឡើង ដើម្បីផ្តល់នូវរបបសន្តិសុខសង្គមរួមមាន ផ្នែកប្រាក់សោធន ផ្នែក-ថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការ-ងារ។ ក្នុងនោះដែរ ផ្នែកនិកម្មភាពការងារ គឺជាសមិទ្ធផលដ៏ថ្មីស្រឡាង មួយ ដែលពុំធ្លាប់មានពីមុនមក នៅក្នុងប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា។

**ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** បានបន្តថា សេចក្តីព្រាងច្បាប់នេះ ពិតជាឧបករណ៍គតិយុត្តដ៏សំខាន់មិនអាចខ្វះបានក្នុងការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម និងបានជម្រុញថ្នាក់ដឹកនាំ នៃ ប.ស.ស ត្រូវខិតខំអនុវត្តឱ្យបានល្អប្រសើរថែមទៀត លើសេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម (ប.ស.ស) ក៏ដូចជាព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធ ដើម្បីឱ្យការអនុវត្តច្បាប់ថ្មីនេះប្រកប ដោយប្រសិទ្ធភាព និងតម្លាភាពបំផុត។

ជាមួយគ្នានេះ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស បានបញ្ជាក់អំពីគោលបំណងលម្អិត នូវខ្លឹមសារនៃសេចក្តីព្រាងច្បាប់នេះ គឺដើម្បីកំណត់អំពីបែបបទ យន្តការអនុវត្ត និងប្រព័ន្ធគ្រប់គ្រងរបបសន្តិសុខសង្គម នៃព្រះរាជាណាចក្រកម្ពុជា ប្រកបដោយគណនេយ្យភាព និងនិរន្តរភាព។



ឯកឧត្តមប្រតិភូ ឡើងថ្លែងអំពីគោលបំណងលំអិតនូវសេចក្តីព្រាងច្បាប់

វិសាលភាពច្បាប់នៃការអនុវត្ត ចំពោះបុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈ និងជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលបុគ្គលិកធ្វើការតាមផ្លូវអាកាស នាវាសមុទ្រ អ្នកបម្រើតាមផ្ទះ និងបុគ្គលស្វ័យនិយោជន៍៕





សិក្ខាកាមចូលរួមក្នុងអង្គសិក្ខាសាលា



# សម្រស់ឯកវាយនភណ្ឌ ប្រចាំឆ្នាំ២០១៨ ទទួលបានជោគជ័យ និងមានការគាំទ្រយ៉ាង ពេញទំហឹងពីសាធារណជន ជាពិសេសកម្មករ កម្មការិនី

**ភ្នំពេញ៖** ព្រឹត្តិការណ៍ដ៏ធំប្រចាំឆ្នាំនេះ រៀបចំឡើងនៅសាលមហោស្រពកោះពេជ្រ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ការប្រឡងសម្រស់ឯកវាយនភណ្ឌឆ្នាំ២០១៨ កាលពីថ្ងៃទី០១ ខែឧសភា គណៈកម្មការវាយតម្លៃការប្រកួតបានប្រកាសជាផ្លូវការនូវបេក្ខជន បេក្ខនារី ដែលជាកម្មករ កម្មការិនីទទួលបានជ័យលាភីសម្រស់ឯកវាយនភណ្ឌឆ្នាំនេះបានទៅលើបេក្ខជនផង និងបេក្ខនារីផង។

- **សម្រាប់បេក្ខជនមាន៖**

- **ជ័យលាភីលេខ១** បានទៅលើបេក្ខជន **ឌិន សិត** មកពីរាជធានីភ្នំពេញ
- **ជ័យលាភីលេខ២** បានទៅលើបេក្ខជន **គង់ ថិតាក់** មកពីរាជធានីភ្នំពេញ
- **ជ័យលាភីលេខ៣** បានទៅលើបេក្ខជន **ទូត ឌិត្យា** មកពីខេត្តព្រះសីហនុ

- **សម្រាប់បេក្ខនារីមាន៖**

- **ជ័យលាភីលេខ១** បានទៅលើបេក្ខនារី **ញៀន ស៊ូវិភញ្ញា** មកពីរាជធានីភ្នំពេញ
- **ជ័យលាភីលេខ២** បានទៅលើបេក្ខនារី **ប៊ិន អ៊ីន** មកពីខេត្ត ព្រះសីហនុ
- **ជ័យលាភីលេខ៣** បានទៅលើបេក្ខនារី **ហុក ណារត្រី** មកពីខេត្តបន្ទាយមានជ័យ





• **រង្វាន់សម្រាប់ បេក្ខជន បេក្ខនារី រួមមាន៖**

- ជ័យលាភីលេខ១ ទទួលបានថវិកា ៥ ០០០ ០០០រៀល និងម៉ូតូ Honda Scoopy ចំនួន ០១គ្រឿង។
- ជ័យលាភីលេខ២ ទទួលបានថវិកា ៤ ០០០ ០០០រៀល និងម៉ូតូ Honda Dream ចំនួន ០១គ្រឿង។
- ជ័យលាភីលេខ៣ ទទួលបានថវិកា ៣ ០០០ ០០០រៀល និងម៉ូតូ Honda Wave ចំនួន ០១គ្រឿង។

• ចំពោះជ័យលាភីកិត្តិយស ទទួលបានថវិកា ២ ០០០ ០០០ រៀល និងអ្នកមិនទទួលបានជ័យលាភី ក៏ទទួលបានថវិកា ចំនួន ១ ០០០ ០០០រៀល ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ។

**ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** បានថ្លែងថា ការរៀបចំកម្មវិធីសម្រស់ឯកវាយនភណ្ឌនេះ ត្រូវបានបង្កើតឡើង ក្រោមគំនិតផ្តួចផ្តើមពី **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានចំនួន ០៣លើក រួចមកហើយគឺនៅ ឆ្នាំ២០១៥ ឆ្នាំ២០១៦ និង២០១៧ ដោយទទួលបានជោគជ័យ និងមានការគាំទ្រយ៉ាងពេញទំហឹងពីសាធារណជន ជាពិសេសកម្មករ កម្មការិនី។

**ឯកឧត្តមបណ្ឌិត** បានបន្តថា ឆ្នាំនេះគឺជាលើកទី៤ហើយ ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំកម្មវិធីសម្រស់ឯកវាយនភណ្ឌ ឱ្យកាន់តែមានលក្ខណៈទូលំទូលាយជាងមុន ដោយមានការចូលរួមពី **សមាគមរោងចក្រកាត់ដេរនៅកម្ពុជារួមមាន (GMAC) សហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក) អគ្គនាយកដ្ឋានវិទ្យុ និងទូរទស្សន៍បាយ័ន ក្រុមប្រឹក្សាសហជីពជាតិកម្ពុជា (CCNU) និងសភាសម្ព័ន្ធសហជីពជាតិកម្ពុជា (NACC) ព្រមទាំងដៃគូរពាក់ព័ន្ធ** នានា សំដៅលើកតម្លៃកម្មករ កម្មការិនី និងបង្កើតនូវបរិយាការងារក្នុងឧស្សាហកម្មផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងនៅកម្ពុជា និងវិស័យសេដ្ឋកិច្ចផ្សេងៗទៀត ក្នុងឱកាសអបអរសាទរខួបអនុស្សាវរីយ៍លើកទី ១៣២ **ទិវាពលកម្មអន្តរជាតិ** ក្រោមប្រធានបទ **«សន្តិភាព ស្ថិរភាព ដើម្បីការងារ និងមុខរបរ»**។

**ឯកឧត្តមបណ្ឌិត** បានលើកទឹកចិត្តដល់កម្មករ កម្មការិនីត្រូវមានការចូលរួមលើកស្ទួយវិស័យកាត់ដេរ និងស្គាល់ពីតម្លៃការងាររបស់ខ្លួនព្រមទាំងសំដៅបង្កើនផលិតភាពការងារ និងទំនាក់ទំនងកាន់តែល្អជាមួយថៅកែ និងគោរពច្បាប់ស្តីពីការងារទាំងអស់គ្នា។ **ឯកឧត្តមបណ្ឌិត** បានបញ្ជាក់ទៀតថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនឹងបន្តរៀបចំកម្មវិធីនេះនៅឆ្នាំក្រោយៗទៀត ហើយសង្ឃឹមថាកម្មករ កម្មការិនីនឹងបន្តចូលរួមក្នុងកម្មវិធីនេះ កាន់តែអធិកអធមថែមទៀត៕







# កិច្ចប្រជុំអន្តរក្រសួង លើសេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម

**ភ្នំពេញ៖** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំប្រជុំអន្តរក្រសួង លើសេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម ក្រោមអធិបតីភាព **ឯកឧត្តម ម៉ម វណ្ណៈ** រដ្ឋលេខាធិការ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម បណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានរៀបចំឡើងរយៈពេល ២ថ្ងៃ គឺចាប់ពីថ្ងៃទី២៨ ដល់ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ នៅទីស្តីការក្រសួង ដោយមានការអញ្ជើញចូលរួមពីគ្រប់តំណាងក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ សរុបប្រមាណជា ៥៥ នាក់។







**ឯកឧត្តម ម៉ម វណ្ណៈ** បានថ្លែងថា សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គមថ្មី រៀបចំឡើងក្នុងគោលបំណងបង្កើតឱ្យមានរបបសន្តិសុខសង្គម សម្រាប់ប្រជាជនទូទៅនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ស្របតាមគោលការណ៍សាមគ្គីធម៌ និងសមធម៌សង្គម ដែលមានចែងនៅក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ រួមមាន ៤ផ្នែកគឺ ៖ ផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការងារ សម្រាប់បុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈ បុគ្គលដែលស្ថិតក្នុងវិស័យឯកជន និងបុគ្គលស្វ័យនិយោជន៍។

**ឯកឧត្តម ម៉ម វណ្ណៈ** បានបន្តថា ច្បាប់ស្តីពីរបបសន្តិសុខសង្គមថ្មីនេះ បានរៀបចំឡើងតាមទម្រង់ណែនាំ និងការសហការជាមួយក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមាន ប.ស.ស ជាសេនាធិការ ក៏បានពិភាក្សាជាមួយក្រុមអ្នកច្បាប់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបានសិក្សាស្រាវជ្រាវ ពិគ្រោះយោបល់ជាមួយក្រុមអ្នកជំនាញការផ្នែកច្បាប់របស់អង្គការអន្តរជាតិខាងការងារ (ILO) ផងដែរ។





ជាមួយគ្នានេះ ក្រុមប្រឹក្សាអ្នកច្បាប់ ប.ស.ស ក៏បានឆ្លងក្រុមការងារអន្តរក្រសួង និងដើម្បីរៀបចំការពិគ្រោះយោបល់ជាសាធារណៈ ចំនួន ៤លើក ។

លើកទី១ បានរៀបចំឡើងកាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម ដែលមានសមាសភាពចូលរួម គ្រប់តំណាងក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា ។

លើកទី២ ត្រូវបានរៀបចំដោយបានធ្វើបទបង្ហាញ ស្តីពីផ្នែកសោធន ជូនដល់គណៈកម្មការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨។



លើកទី៣ រៀបចំប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម មានសមាសភាពចូលរួម តំណាងអង្គការ ILO សហភាពសហព័ន្ធសហជីព កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ និងលើកទី៤ បានរៀបចំប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម មានសមាសភាពចូលរួម តំណាងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា តំណាងសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា ដែលបានធ្វើឡើងកាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨៕



# ពិធីចែកប័ណ្ណបើកបរ ដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិតនៅរោងចក្រ SABRINA (CAMBODIA) GARMENT MANUFACTURING CORP ខេត្តកំពង់ស្ពឺ



**កំពង់ស្ពឺ៖ ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.) អញ្ជើញជាអធិបតីក្នុងពិធីចែកប័ណ្ណបើកបរជូនអ្នកបើកបរយានយន្តដឹកកម្មករនិយោជិត ស្ថិតនៅរោងចក្រ SABRINA (CAMBODIA) GARMENT MANUFACTURING CORP ខេត្តកំពង់ស្ពឺ កាលពីថ្ងៃសុក្រ ១៤រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨ ។ **ឯកឧត្តមប្រតិភូ** បានថ្លែងថា៖ ក្រុមអ្នកបើកបររថយន្តដឹកជញ្ជូនកម្មករកម្មការិនី នៅរោងចក្រសាប្រីណាចំនួន ៦៨នាក់ ដែលទទួលប័ណ្ណបើកបរ នៅពេលនេះ គឺជាផ្លែផ្កាមួយក្នុងចំណោមផ្លែផ្កាជាច្រើនទៀតដែលបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយអគ្គនាយកនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណៈការ និង ដឹកជញ្ជូនធ្វើការបណ្តុះបណ្តាល និងធ្វើការប្រឡងទាំងទ្រឹស្តី និងការកាន់ដៃចង្កូតបើកបរយ៉ាងត្រឹមត្រូវទៅតាមច្បាប់ដែលបានកំណត់។

**ឯកឧត្តមប្រតិភូ** បានថ្លែងបន្តថា៖ អ្នកបើកបរយានយន្តដឹកកម្មករកម្មការិនីទាំងអស់ បើចេះច្បាប់ហើយមានប័ណ្ណបើកបរហើយ ដាច់ខាតត្រូវគោរពច្បាប់ចរាចរណ៍ពិសេសត្រូវគោរពក្រមសីលធម៌វិជ្ជាជីវៈ ជំនាញជាអ្នកបើកបរឱ្យបានត្រឹមត្រូវគ្រប់ពេលវេលា និងមិនត្រូវធ្វេសប្រហែសនោះឡើយ ព្រោះថាអាយុជីវិតកម្មករកម្មការិនីទាំងអស់ ត្រូវបានពឹងផ្អែកទាំងស្រុងទៅលើអ្នកបើកបរយានយន្តទាំងពេល ទៅបំពេញការងារ និងពេលត្រឡប់មកវិញផង។



ស្រប ជាមួយ គ្នានេះដែរ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាកន្លងមកបានផ្តល់អនុសាសន៍ថា "ថ្ងៃនេះ ថ្ងៃស្អែក កុំឱ្យមានគ្រោះថ្នាក់ចរាចរណ៍"។ គ្រោះថ្នាក់ចរាចរណ៍ដែលកើតឡើងដោយការមិនគោរពច្បាប់ចរាចរណ៍ឱ្យបានត្រឹមត្រូវ មិនត្រឹមតែធ្វើឱ្យបាត់បង់មនុស្សជាទីស្រឡាញ់ ឬពិការអស់មួយជីវិតនៅលើទ្រូងផ្លូវសាធារណៈនោះទេ ប៉ុន្តែវាបណ្តាលឱ្យខាតបង់សេដ្ឋកិច្ច គ្រួសាររួមទាំងសេដ្ឋកិច្ចជាតិទាំងមូលផងដែរ។

យោងតាមរបាយការណ៍ ពីក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) បានបង្ហាញថា៖ នៅខែកក្កដា ឆ្នាំ២០១៨នេះ មានកម្មករកម្មការិនីរងគ្រោះថ្នាក់ចរាចរណ៍ក្នុងពេលធ្វើដំណើរទៅ និងមកបំពេញការងារ នៅក្នុងទូទាំងប្រទេសមានចំនួន ១៨៣នាក់ ដោយ សារការល្មើសច្បាប់ចរាចរណ៍។



ពាក់ពន្ធ័នឹងបញ្ហានេះ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) បានបញ្ជាក់ថា៖ ចាប់ពីឆ្នាំ២០១៣ រហូតដល់ ខែកក្កដា ឆ្នាំ២០១៨នេះ ក្រុមការងារបានបណ្តុះបណ្តាល និងប្រឡងយកប័ណ្ណបើកបរ ដល់អ្នកបើកបរយានយន្តដឹកកម្មករ-កម្មការិនី បានចំនួន ២២៣លើក មានអ្នកចូលរួមសរុបចំនួន ១០ ៤៧២នាក់។ ក្នុងនោះ ប្រឡងយកប័ណ្ណបើកបរចំនួន ៤៥លើក អ្នកបើកបរចូលរួមសរុប ៣ ៤៨៥នាក់ ជាប់ជាស្ថាពរចំនួន ២ ៤១២នាក់ ផ្តល់ប័ណ្ណបើកបរដល់អ្នកបើកបររថយន្តដឹកកម្មករចំនួន២៣លើក អ្នកដែលត្រូវទទួលប័ណ្ណ ចំនួន ២០៦០នាក់។ សម្រាប់ខែមករា ដល់ខែកក្កដា ឆ្នាំ២០១៨ នេះ ក្រុមការងារបានប្រជុំផ្សព្វផ្សាយអប់រំដល់អ្នកបើកបររថយន្តដឹកកម្មករបានចំនួន ១៤៨លើក អ្នកចូលរួម ២៩ ៥៦២នាក់។ បណ្តុះបណ្តាល ចំនួន ៧៣លើក អ្នកចូលរួម ២ ៩៣៥នាក់ ប្រឡងយកប័ណ្ណបើកបរចំនួន ០៥លើក អ្នកចូលរួមសរុប ៣៦៥នាក់ ជាប់ជាស្ថាពរចំនួន ៣៥២នាក់ ។

បច្ចុប្បន្នភាពចំនួនយានយន្តដឹកកម្មករនិយោជិតទូទាំងប្រទេស នៅក្នុងឆ្នាំ២០១៨ មានចំនួន ៤ ៣៦៩គ្រឿង (រថយន្តទេសចរណ៍ចំនួន ១ ៤៨០គ្រឿង ស្មើនឹង ៣៤% និងរថយន្តប្រភេទដឹកទំនិញចំនួន ២ ៨៨៩គ្រឿង ស្មើនឹង ៦៦%) ក្នុងនោះអ្នកមានប័ណ្ណ ៣ ៨៥៥នាក់ ស្មើនឹង ៨៨% និងអ្នកគ្មានប័ណ្ណ ៥១៤នាក់ ស្មើនឹង ១២% ។



តាមរបាយការណ៍នេះ បានបញ្ជាក់ថា បច្ចុប្បន្នអ្នកបើកបរយានយន្តដឹកកម្មករចំនួន ១៨% ពុំទាន់មានប័ណ្ណបើកបរ និងអ្នកបើកបរយានយន្តដឹកកម្មករចំនួន ៨៥%ផ្សេងទៀតពុំទាន់មានប័ណ្ណបើកបរស្រប តាមប្រភេទ យាន យន្តដែលទាមទារ ឱ្យមាន ការចូលរួមក្នុងបណ្តុះបណ្តាលបន្ថែមទៀតពីអ្នកបើកបរយានយន្ត ដើម្បីចេះច្បាប់ចរាចរណ៍ និងយកទៅអនុវត្តឱ្យបានច្បាស់លាស់ត្រឹមត្រូវ៕





# កម្មករនិយោជិតនៅពេលចាស់ជរាអាចចិញ្ចឹមខ្លួនឯងបាន នៅពេលច្បាប់ស្តីពីរបបសន្តិសុខសង្គមថ្មីដាក់ឱ្យអនុវត្ត



**រាជធានីភ្នំពេញ៖ ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស បានថ្លែងថា ៖ ច្បាប់ស្តីពីរបបសន្តិសុខសង្គម នៃព្រះរាជាណាចក្រកម្ពុជា នឹងដាក់ឱ្យអនុវត្តក្នុងពេលឆាប់ៗ ខាងមុខនេះ ដែលមានវិសាលភាពគ្របដណ្តប់លើ បុគ្គលក្នុងវិស័យសាធារណៈ បុគ្គលក្រោមច្បាប់ការងារ នាវាសមុទ្រ អ្នកបម្រើតាមផ្ទះ និងបុគ្គលស្វ័យនិយោជន៍។



**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានថ្លែងយ៉ាងដូច្នេះ នៅក្នុងកិច្ចប្រជុំពិនិត្យ និងកែសម្រួលខ្លឹមសារលើសេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម ជាមួយប្រធានសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា កាលពីថ្ងៃព្រហស្បតិ៍ ១០កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨កន្លងមកនេះ ដែលប្រារព្ធធ្វើឡើងនៅសាលប្រជុំបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានសង្ឃឹមយ៉ាងមុតមាំថា សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គមនេះ នឹងធ្វើឱ្យបុគ្គលិកដែលស្ថិតនៅក្រោមច្បាប់ស្តីពីរបបសន្តិសុខសង្គម នឹងជួយឱ្យជីវភាពរបស់កម្មករនិយោជិតនៅពេលចាស់ជរាអាចចិញ្ចឹមខ្លួនឯងបាន ដោយមិនចាំបាច់ពឹងផ្អែកទៅលើកូនចៅទាំងស្រុងនោះឡើយ។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** ក៏បានលើកឡើងផងដែរ ថា នៅពាក់កណ្តាលឆ្នាំ ២០១៩ នេះយើងបានសិក្សាហើយប្រកាសចេញជាក្របខណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាលនិងមានការអនុវត្តចំពោះស្ត្រីក្រីក្រដែលមានផ្ទៃពោះនិងឆ្លងទន្លេ ដោយទទួលបានថវិកាពីរាជរដ្ឋាភិបាលរហូត ដល់៧៦ម៉ឺនរៀល វាច្រើនជាងកម្មការិនីដែលបានតែ ៤០ម៉ឺនរៀល ៧៦ម៉ឺនរៀល វាច្រើនជាងកម្មការិនី ដែលបានតែ ៤០ម៉ឺនរៀល និងសុំអធ្យាស្រ័យចំពោះបងប្អូនដែលជាស្ត្រីនៅទូទាំងប្រទេស ដោយថវិកាមិនអាចផ្តល់ឱ្យបានគ្រប់គ្នាទេ ព្រោះនេះគឺជាសមធម៌សម្រាប់អ្នកក្រីក្រដែលរាជរដ្ឋាភិបាលជួយ៕



# ពិធីប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយ នៃការអនុវត្ត របបសន្តិសុខសង្គម ដល់និយោជិត ម្ចាស់ សហគ្រាស គ្រឹះស្ថាន នៅខេត្តកំពង់ឆ្នាំង

**កំពង់ឆ្នាំង៖** បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីថ្ងៃអង្គារ ៧រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨ បានសហការជាមួយរដ្ឋបាលខេត្តកំពង់ឆ្នាំង បើកកិច្ចប្រជុំស្តីពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម ដល់និយោជក ម្ចាស់ សហគ្រាស គ្រឹះស្ថាន តំណាងជនរងគ្រោះ ដែលកំពុងទទួលបានតាវកាលិក បាត់បង់សមត្ថភាពអចិន្ត្រៃយ៍ និងឧត្តរជីវី ចំនួន ១៧៨នាក់ នៅសាលាខេត្តកំពង់ឆ្នាំង។




កិច្ចប្រជុំផ្សព្វផ្សាយនេះ រៀបចំឡើងក្រោមអធិបតីភាព **ឯកឧត្តម ហ៊ី ណាត** អភិបាលរង តំណាងឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តកំពង់ឆ្នាំង និង**ឯកឧត្តម ម៉េង ហុង** នាយករង ប.ស.ស ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស ព្រមទាំងមានការចូលរួមពីថ្នាក់ដឹកនាំមន្ទីរ អង្គភាពចំណុះរដ្ឋបាលខេត្តកំពង់ឆ្នាំង ព្រមទាំងមន្ត្រី និងបុគ្គលិកសាខា ប.ស.ស ខេត្ត មូលដ្ឋានសុខាភិបាលចុះកិច្ចព្រមព្រៀងជាច្រើនទៀតផងដែរ។





ផ្តើមចេញពីនេះ **ឯកឧត្តម ហ៊ី ណាត** អភិបាលរងខេត្តបានថ្លែងអំណរគុណដល់បេឡាជាតិរបបសន្តិសុខសង្គម ដែលបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយនេះឡើងពិសេសទាក់ទងទៅនិងការធានារ៉ាប់រងលើរបបសន្តិសុខសង្គម សម្រាប់កម្មករនិយោជិតទាំងក្នុង និងក្រៅប្រព័ន្ធ ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងគោលនយោបាយ កាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលតាមរយៈការបន្ថយនូវគម្លាតប្រាក់ចំណូលរវាងអ្នកមាន និងអ្នកក្រ ដើម្បីធានាស្ថិរភាព និងភាពសុខដុមរមនានៅក្នុងសង្គម។



ជាមួយគ្នានេះ **ឯកឧត្តម ម៉េង ហុង** បានថ្លែងបញ្ជាក់ថា៖ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) មានសាខាទាំង ២៥ ខេត្ត/ក្រុង នៅទូទាំងប្រទេស បច្ចុប្បន្នផ្នែកហានិភ័យការងារមានសហគ្រាស សរុបចំនួន ១១,៦៩៦សហគ្រាស បានចុះបញ្ជិកា ដែលមានសមាជិកសរុប ១,៤៥២,៣៤១នាក់ និងបានចុះកិច្ចព្រមព្រៀងជាមួយមន្ទីរពេទ្យ មណ្ឌលសុខភាព ក្នុងការផ្តល់សេវាជូនសមាជិក ប.ស.ស ចំនួន ១,៣១៧មូលដ្ឋានសុខាភិបាលផងដែរ។ ទន្ទឹមគ្នានេះតាវកាលិកដែលសមាជិក ប.ស.ស អាចទទួលបានរួមមាន៖ សេវាសង្គ្រោះបន្ទាន់ សេវាថែទាំ និងព្យាបាល ទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ ទទួលបានប្រាក់ធនលាភ និងប្រាក់វិភាជន៍សោហ៊ុយបូជាសព តាវកាលិកឧត្តរជីវី សេវាស្តារនីតិសម្បទា និងការសម្របសម្រួលវិជ្ជាជីវៈឡើងវិញ។



ដោយឡែកផ្នែកថែទាំសុខភាព គឺសំដៅដល់ការធានារ៉ាប់រងសុខភាពសង្គមដូចជា៖ សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ សេវាបង្ការសុខភាព ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការអាក់ខានការងារដោយការព្យាបាលជំងឺ ឬគ្រោះថ្នាក់ផ្សេង ៗ ក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។

បើគិតរហូតមកដល់ពេលបច្ចុប្បន្ននេះ មានសហគ្រាសចុះបញ្ជិកាចំនួន ៦,១៦៣សហគ្រាស ដែលមានសមាជិកចំនួន ១ ៣៤៨ ៨១៨ នាក់ ស្រី ៩៨៣ ២១៧នាក់។



បន្ថែមពីនេះទៀត **ឯកឧត្តម** បានលើកឡើងផងដែរ ស្តីពីអនុក្រឹតលេខ១៤០ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៧ នៃអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ ពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។

ដូច្នេះសម្រាប់និយោជក ម្ចាស់សហគ្រាស គ្រឹះស្ថានគប្បីមានការ យល់ដឹងកាន់តែច្បាស់ ពីការបង្ការគ្រោះថ្នាក់ការងារ ការយកចិត្តទុកដាក់ពីសុខភាព សុវត្ថិភាពអនាម័យ និងសុវត្ថិភាពក្នុងពេលធ្វើដំណើរទៅនិងមកពីបំពេញភារកិច្ចរបស់បុគ្គលិក កម្មករនិយោជិត នៅតាមសហគ្រាស គ្រឹះស្ថានដែលពាក់ព័ន្ធនឹងការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ ការផ្តល់សេវារបស់មន្ត្រី ប.ស.ស សាខាខេត្ត សេវាសុខាភិបាលរបស់មន្ទីរពេទ្យដែលចុះកិច្ចព្រមព្រៀង ព្រមទាំងការផ្តល់សេវាពាក់ពន្ធ័ និងធនាគារអេស៊ីលីដាភីអិលស៊ី ធនាគារកាណាឌីយ៉ា ធនាគារឯកទេសវីង ដែលជាដៃគូក្នុងការផ្តល់សេវាទាំងនេះផងដែរ។

# គ្មានការរើសអើងណាមួយ ក្នុងការប្រើប្រាស់ប័ណ្ណសមាជិក ប.ស.ស នៅគ្រប់បណ្ដាមូលដ្ឋានសុខាភិបាល ជាដៃគូរបស់ ប.ស.ស

**រាជធានីភ្នំពេញ៖ ឯកឧត្តម ម៉េង ហុង** នាយករង ប.ស.ស បានឱ្យដឹងថា បងប្អូនកម្មករនិយោជិតដែលទៅទទួលសេវាសុខភាពនៅតាមមន្ទីរពេទ្យជាដៃគូរ ប.ស.ស គឺទទួលបានគុណភាពនៃការព្យាបាល និងថ្នាំដូចអតិថិជនដែលបង់លុយដែរ បានន័យថា គ្មានការរើសអើងណាមួយ ក្នុងការទៅទទួលសេវាសុខភាព តាមរយៈប័ណ្ណ ប.ស.ស នៅគ្រប់មន្ទីរពេទ្យជាដៃគូរបស់ ប.ស.ស នោះទេ ហើយប័ណ្ណសមាជិក ប.ស.ស ដែលបានផ្ដល់ជូនបងប្អូននេះ គឺមិនមានកំណត់សុពលភាពនោះដែរ ។





**ឯកឧត្តម ម៉េង ហុង** បានថ្លែងបែបនេះ នៅក្នុងពិធីប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយ នៃការអនុវត្តរបបសន្តិសុខសង្គម ដល់រដ្ឋបាលរោងចក្រ ប្រតិភូបុគ្គលិក សហជីពមូលដ្ឋាន និងកម្មករ កម្មការិនី ចំនួន ៥៩នាក់ នៅរោងចក្រ Roo Hsing Garment Co., Ltd កាលពីថ្ងៃចន្ទ ១៣រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រារព្ធធ្វើឡើងនៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

ការថ្លែងបែបនេះ ពាក់ព័ន្ធ និងកិច្ចប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម។ នៅក្នុងពេលនោះដែរ **ឯកឧត្តម** បានធ្វើការពង្រឹងសេវានៃការផ្ដល់តាវកាលិកជូនបងប្អូនកម្មករនិយោជិត ដែលទាក់ទងទៅនឹងផ្នែកហានិភ័យការងារ គឺបានន័យថា ជាគ្រោះថ្នាក់ទាំងឡាយណា ដែលកើតឡើងក្នុងកំឡុងពេលបំពេញការងារ ពេលធ្វើដំណើរពីផ្ទះទៅកន្លែងធ្វើការ និងពីកន្លែងធ្វើការត្រលប់ទៅផ្ទះវិញ ដោយមិនមានការវាងចូលកន្លែងណាមួយជាប្រយោជន៍ផ្ទាល់ខ្លួន និងជំងឺវិជ្ជាជីវៈ។

**ឯកឧត្តម** បានបន្ថែមទៀតថា បច្ចុប្បន្ននេះ ប.ស.ស មានសាខានៅតាម បណ្ដារាជធានី/ខេត្ត ទាំង២៥ និងមានសហគ្រាស គ្រឹះស្ថាន ចុះបញ្ជិកាសរុបចំនួន ១១ ៨១៤សហគ្រាស សមាជិកសរុប ១ ៤៥៦ ២៤១នាក់ ជាពិសេសមានមន្ទីរពេទ្យបង្អែក មន្ទីរពេទ្យមណ្ឌលសុខភាពដែលជាដៃគូ ប.ស.ស ក្នុងការផ្ដល់សេវាជូនសមាជិក ប.ស.ស ចំនួន ១ ៣១៩ មន្ទីរពេទ្យ ដោយឥតគិតថ្លៃ៕



# គិតត្រឹមថ្ងៃទី០១ មករា ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ រាជរដ្ឋាភិបាល បានផ្តល់ថវិកាជាង ៩ពាន់លានរៀល ជូនកម្មការិនីដែលបានសម្រាលកូន សរុបចំនួន ២៣ ២៩៣នាក់



**រាជធានីភ្នំពេញ៖ ឯកឧត្តម ជាវ ម៉ុនរិទ្ធ** អ្នកនាំពាក្យបេឡាជាតិរបបសន្តិសុខសង្គម បានឱ្យដឹងថា គិតចាប់ពីថ្ងៃទី០១ ខែមករា រហូតមកដល់ព្រឹកថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨កន្លងមកនេះ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអនុវត្តកម្មវិធីបើកផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលដល់កម្មករនិយោជិតជាស្ត្រីសម្រាលកូនបានចំនួន ២៣ ១២៨នាក់ ដែលមានកូនសរុបចំនួន ២៣ ២៩៣នាក់ សរុបជាទឹកប្រាក់ចំនួន ៩ ៣១៧ ២០០ ០០០រៀល។

**ឯកឧត្តម** ថ្លែងបន្តថា ប.ស.ស បានអនុវត្តគោលការណ៍បើកផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូននេះ ដោយអនុលោមតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលទាក់ទងទៅនិងរបបប្រាក់ឧបត្ថម្ភបន្ថែមពីរាជរដ្ឋាភិបាលដូចជា៖

- សំរាប់ស្ត្រីសម្រាលបានកូន១នាក់ គឺទទួលបានប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលចំនួន ៤០ម៉ឺនរៀល
- សម្រាលបានកូនភ្លោះ២នាក់ គឺទទួលបានប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលចំនួន ៨០ម៉ឺនរៀល




- សម្រាលបានកូនភ្លោះ៣នាក់ គឺទទួលបានប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលចំនួន ១២០ម៉ឺនរៀល។ ពិសេសកូនភ្លោះ០៣នាក់ទទួលបានថវិកាចំនួន៥លានរៀល។

ទាំងនេះ គឺជាការយកចិត្តទុកដាក់ពីសំណាក់ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលលោកតែងតែគិតគូរអំពីទុក្ខលំបាករបស់ បងប្អូនកម្មករនិយោជិត និងប្រជាពលរដ្ឋជារៀងដរាបមក ៕

# បេឡាជាតិរបបសន្តិសុខសង្គម ប.ស.ស បានចាត់បញ្ជូនមន្ត្រីជំនាញ ចូលរួមសិក្ខាសាលាស្តីពីគោលនយោបាយហិរញ្ញប្បទានសុខាភិបាល ក្នុងតំបន់លើកទី៣ នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម

**ប្រទេសវៀតណាម៖ លោក អេាក ឡៃស៊** មន្ត្រីការិយាល័យធានារ៉ាប់រងសុខភាព នៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមសិក្ខាសាលាស្តីពីគោលនយោបាយហិរញ្ញប្បទានសុខាភិបាលក្នុងតំបន់ លើកទី៣ របស់អង្គការសុខភាពពិភពលោក ដើម្បីឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសាកល នៅក្នុងតំបន់អាស៊ី។

សិក្ខាសាលានេះប្រព្រឹត្តិទៅរយៈពេល ០៤ថ្ងៃ គឺចាប់ពីថ្ងៃទី២៥ ខែមិថុនា ដល់ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ នៅទីក្រុងហូជីមិញ (Ho Chi Minh) ប្រទេសវៀតណាម ក្នុងគោលបំណងដើម្បី៖

១.បន្តតាមដានសកម្មភាព និងបញ្ហាប្រឈមនានាស្តីពីគោលនយោបាយហិរញ្ញប្បទានសុខាភិបាលក្នុងតំបន់លើកទី២របស់អង្គការសុខភាពពិភពលោក ដើម្បីឆ្ពោះទៅរកការគ្របដណ្តប់ សុខភាពជាសាកល នៅក្នុងតំបន់អាស៊ី កាលពីខែមិថុនា ឆ្នាំ ២០១៧ កន្លងមក។

២.ដើម្បីចែករំលែកបទពិសោធន៍ពីបណ្តាប្រទេសផ្សេងៗ និងការចូលរួមសហការគ្នាលើអទិភាពផែនការ ថវិកាហិរញ្ញប្បទានសុខាភិបាល និងការថែទាំសុខភាពជាពិសេស ចុះកិច្ចព្រមព្រៀងជាមួយ មូលដ្ឋានសុខាភិបាល ការគ្រប់គ្រង និងវាយតម្លៃប្រព័ន្ធទូទាត់សំណង។






៣.ដើម្បីកំណត់គោលការណ៍រួម និងចំណុចពាក់ព័ន្ធ តាមបណ្តាប្រទេសនីមួយៗ ដើម្បីមានយុទ្ធសាស្ត្រទិញច្បាស់លាស់ ។ ជាមួយគ្នានេះ ក៏មានការលើកឡើងពីបញ្ហាប្រឈមនានាក្នុងការ អនុវត្តការងារជាក់ស្តែងនៅក្នុងថ្នាក់តំបន់ និងបញ្ហាមួយចំនួន ត្រូវបានដោះស្រាយជាបន្តបន្ទាប់។

គួររំលឹកផងដែរថា បច្ចុប្បន្ន ប.ស.ស បាននឹងកំពុងដំណើរការរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ដែលបងប្អូនកម្មករនិយោជិតជាសមាជិក ប.ស.ស ទាំងអស់អាចទៅទទួលសេវាពិនិត្យ និងព្យាបាលជំងឺនៅតាមមន្ទីរពេទ្យដែលជាដៃគូរបស់ ប.ស.ស បានដោយឥតគិតថ្លៃព្រមទាំងទទួលបានអត្ថប្រយោជន៍ផ្សេងៗជាច្រើនទៀតដែល ប.ស.ស បានផ្តល់ជូន ហើយអ្វីដែលពិសេសជាងនេះទៅទៀតនោះ ដោយមានការយកចិត្តទុកដាក់ពីសំណាក់ប្រមុខរាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមាន ប.ស.ស ជាសេនាធិការនឹងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន (ប្រាក់រ៉ឺត្រេត) នៅក្នុងឆ្នាំ២០១៩ ខាងមុខនេះ ដើម្បីឱ្យបងប្អូនកម្មករនិយោជិតទាំងអស់ទទួលបានប្រាក់រ៉ឺត្រេត បន្ទាប់ពីពួកគាត់បានបំពេញគ្រប់អតីតភាពការងារ ៕

# ដំណើរទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរយោបល់ និងដកស្រង់ បទពិសោធន៍ នៅប្រទេសថៃ




**ប្រទេសថៃ៖** កាលពីថ្ងៃអង្គារ ១៤កើត ខែបឋមសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ កន្លងមកនេះ បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចាត់មន្ត្រីចំនួន ២២រូប ចូលរួមទស្សនកិច្ចសិក្សា និងពិភាក្សាស្តីពីការគ្រប់គ្រងការិយាល័យថ្នាក់តំបន់ ដើម្បីគាំទ្រការថៃទាំសុខភាពសាកល (UHC) នៅការិយាល័យថ្នាក់តំបន់ នៃការិយាល័យសន្តិសុខសុខភាពជាតិ ទី១៣ ស្ថិតនៅទីក្រុងបាំងកកប្រទេសថៃ ក្នុងអគារចម្រុះរបស់រដ្ឋាភិបាល (Government Complex Building)។



ដំណើរទស្សនកិច្ចសិក្សានេះដែរ បានផ្តោតសំខាន់ទៅលើ៖

១.ស្វែងយល់ពីប្រព័ន្ធគ្រប់គ្រងដែលគាំទ្រដល់របបធានារ៉ាប់រងសាកល (UCS) ដែលជាការងាររដ្ឋបាល និងត្រួតពិនិត្យសេវាសុខាភិបាល ពីអ្នកផ្តល់សេវាសុខភាព។

២. ស្វែងយល់ពីប្រព័ន្ធអភិបាលកិច្ចដើម្បីស្វែងយល់ពីការគ្រប់ គ្រង។



៣.ចែករំលែកបទពិសោធន៍ ការគ្រប់គ្រងការិយាល័យថ្នាក់តំបន់ដើម្បីគាំទ្រដល់ការថៃទាំសុខភាពសាកល(UHC)។

៤. ពិភាក្សាចំណុចខ្លាំង ចំណុចខ្សោយនិងបញ្ហាប្រឈមនៃការគ្រប់គ្រងថ្នាក់តំបន់ ដើម្បីគាំទ្រក្នុងការថៃទាំសុខភាពសាកល (UHC)។

៥. ទទួលបានការយល់ដឹងស៊ីជម្រៅពីការគ្រប់គ្រងការិយាល័យថ្នាក់តំបន់ ពីការអនុវត្តជាក់ស្តែង និងកំណត់កិច្ចសហប្រតិបត្តិការដែលអាចមាននៅពេលអនាគត។





សូមបញ្ជាក់ផងដែរថា នាពេលបច្ចុប្បន្នបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកំពុងដំណើរការរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ដែលបងប្អូនកម្មករនិយោជិតជាសមាជិក ប.ស.ស អាចទៅទទួលសេវាពិនិត្យ និងព្យាបាលជំងឺនៅតាមមន្ទីរពេទ្យដែលជាដៃគូររបស់ ប.ស.ស ដោយឥតគិតថ្លៃ ព្រមទាំងទទួលបានអត្ថប្រយោជន៍ផ្សេងៗជាច្រើនទៀត ដែល ប.ស.ស បានផ្តល់ជូន។

ពិសេសជាងនេះទៅទៀត ដោយមានការយកចិត្តទុកដាក់ពីសំណាក់ ប្រមុខរាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមាន ប.ស.ស ជាសេនាធិកា នឹងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន (ប្រាក់រ៉ឺត្រែត) នៅក្នុងឆ្នាំ២០១៩ ខាងមុខនេះ ដើម្បីឱ្យបងប្អូនកម្មករនិយោជិតទាំងអស់ទទួលបានបន្ទាប់ពីពួកគាត់បានបំពេញគ្រប់អតីតភាពការងារ ៕



# កិច្ចប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយអភិវឌ្ឍន៍ វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាសង្គ្រោះបឋម





**រាជធានីភ្នំពេញ៖** លោក **ហែម សុគន្ធារិន** អនុប្រធានការិយាល័យគោលនយោបាយ នៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានលើកឡើងថាកម្មករនិយោជិតក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ទាំងអស់មានសិទ្ធិទទួលបានការគាំពារសង្គមពីរាជរដ្ឋាភិបាលតាមរយៈការផ្តល់នូវរបបសន្តិសុខសង្គមពី ប.ស.ស ជាពិសេសការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូនដល់កម្មករនិយោជិតជាស្ត្រីដែលបានសម្រាលកូនទាំងក្នុង និងក្រៅប្រព័ន្ធផងដែរ។

លោកបានលើកឡើងដូចនេះ នៅក្នុងពិធីប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាសង្គ្រោះបឋម ដល់និយោជក ម្ចាស់សហគ្រាស គ្រឹះស្ថាន ក្រោមអធិបតីភាពលោក **ថេង សុថុល** អភិបាល រង តំណាងឯកឧត្តមអភិបាល នៃគណៈអភិបាលខណ្ឌច្បារ អំពៅ កាលពីថ្ងៃព្រហស្បតិ៍ ១០កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨ នៅ សាលាខណ្ឌច្បារអំពៅ។ លោកបានឱ្យដឹងថា ក្នុងត្រីមាសទី១ ឆ្នាំ២០១៨ មានសមាជិក ប.ស.ស ទៅទទួលសេវាផ្នែក ថែទាំសុខភាពសរុបចំនួន ៣០៤ ៩៨៥នាក់ ក្នុងនោះស្ត្រីចំនួន ២៤៣ ៩៨៨នាក់ នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ចំនួន ១ ៣១៧ មូលដ្ឋាននៅទូទាំងរាជធានី/ខេត្ត។ ម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវមាន កាតព្វកិច្ចចុះបញ្ជិកាកម្មករនិយោជិតមកក្នុង ប.ស.ស ដោយខានពុំបាន ដើម្បីឱ្យបងប្អូនកម្មករនិយោជិត ទទួលបានសិទ្ធិទៅប្រើប្រាស់សេវានៅមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ដោយឥតគិតថ្លៃ។

លោក **ថេង សុថុល** បានសម្តែងនូវក្តីរីករាយដែលបានសហការជាមួយ ប.ស.ស បើកកិច្ចប្រជុំផ្សព្វផ្សាយពេលនេះ។ លោកបានបន្តថា កិច្ចសហការជាមួយ ប.ស.ស នាពេលនេះ នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយអំពីវិជ្ជាសង្គ្រោះបឋម និងអត្ថប្រយោជន៍របបសន្តិសុខសង្គមជាច្រើនទៀត ដល់និយោជក ម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលជាក្បាលព្រួញដ៏មុតស្រួចក្នុងការនាំយកទៅផ្សព្វផ្សាយបន្តដល់បងប្អូនកម្មករនិយោជិត៕



# ប.ស.ស សហការជាមួយក្រសួងមហាផ្ទៃផ្សព្វផ្សាយ យន្តការផ្តល់អត្តសញ្ញាណប័ណ្ណដល់បងប្អូនកម្មករនិយោជិត



**ឧត្តរមានជ័យ៖** កាលពីថ្ងៃព្រហស្បតិ៍ ១១រោច ខែ ពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១០ ខែ ឧសភា ឆ្នាំ ២០១៨ ក្រុមការងារបច្ចេកទេសព័ត៌មានវិទ្យាសម្រាប់កំណត់គោលដៅអត្តសញ្ញាណកម្មករនិយោជិត របស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំពិធីប្រជុំផ្សព្វផ្សាយស្តីពីនីតិវិធី និងយន្តការនៃការ ផ្តល់អ ត្តស ញ្ញាណ ប័ណ្ណស ញ្ជាតិខ្មែរ នៅសាលាខេត្តឧត្តរមានជ័យ។



កិច្ចប្រជុំផ្សព្វផ្សាយនេះធ្វើឡើងក្រោម អធិបតីភាព-ឧត្តមសេនីយ៍ឯក **ឃៀង សុគន្ធា** ប្រធាននាយកដ្ឋានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលោក **ឌី ស្មី** ប្រធានការិយាល័យ ព័ត៌មានវិទ្យា ព្រម ទាំង មាន ការ ចូល រួម ពីស្នង ការ រ ង ខេត្តឧត្តរមានជ័យ លោកអធិការ លោកអធិការរងស្រុក/ក្រុងទាំង៥ និងតំណាងនិយោជក នាយកសហគ្រាស គ្រឹះស្ថានចំនួន ៨៥នាក់ផងដែរ។ អ្វីដែលកិច្ចប្រជុំនេះបានប្រព្រឹត្តទៅ គឺការបញ្ជ្រាបកិច្ចសហការរវាង ប.ស.ស និងនាយកដ្ឋានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ នៃក្រសួងមហាផ្ទៃ ក៏ដូចជាផ្សព្វផ្សាយការងារសម្រេចបាន និងយន្តការនៃការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ជូនសមាជិក ប.ស.ស ក៏ដូចជាធ្វើកាផ្សព្វផ្សាយ នឹងបទបង្ហាញអំពីវឌ្ឍនៈភាពថ្មីៗ នៃប្រព័ន្ធព័ត៌មានវិទ្យាដែលមានដូចជា ប្រព័ន្ធជូនដំណឹងហានិភ័យការងារ ONLINE និងប្រព័ន្ធណាត់ជួបមន្ទីរពេទ្យតាម ONLINE (Booking Appointment Online) ផងដែរ៕

# ប ស ស សហការជាមួយគ្រូពេទ្យ TYDA ចុះពិនិត្យព្យាបាលជំងឺជូនបងប្អូន កម្មករនិយោជិតនៅក្នុងសង្កាត់ទឹកថ្លា

**រាជធានីភ្នំពេញ៖** ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយ **សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ (TYDA)** ចុះពិនិត្យព្យាបាលជំងឺជូនបងប្អូនកម្មករនិយោជិតនៅសង្កាត់ទឹកថ្លាកាលពីថ្ងៃអាទិត្យ ១៣កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០១៨។



លោក **យ៉ាម យុទ្ធា** មន្ត្រីបេឡាជាតិរបបសន្តិសង្គម បានឱ្យដឹងថា កន្លងមកក្រុមការងារ ប.ស.ស បានសហការជាមួយសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ បានចំនួន ៣លើករួចមកហើយ នេះជាលើកទី៤ ដែលក្រុមការងារបានទទួលអ្នកជំងឺចំនួន ៣៨០នាក់ ក្នុងនោះមានអ្នកជំងឺសើរស្បែកចំនួន ៥៥នាក់ ជំងឺកុមារចំនួន ៥០នាក់ ជំងឺមាត់ធ្មេញចំនួន ១៨នាក់ និងចុះអប់រំពីបញ្ហាអនាម័យ (មាត់ធ្មេញ) នៅតាមខ្នងផ្ទះបានចំនួន ៤៣៦គ្រួសារ។



មន្ត្រីបេឡាជាតិរបបសន្តិសង្គម បានបញ្ជាក់ឱ្យដឹងទៀតថា ចំពោះបងប្អូនកម្មករ កម្មការិនី ដែលនៅក្រៅប្រព័ន្ធវិញ ក៏អាចទទួលបានសេវាពិនិត្យ និងថែទាំវេជ្ជសាស្ត្រ នៅតាមមន្ទីរពេទ្យ ដែលជាដៃគូររបស់ ប.ស.ស ទាំងនៅក្នុងរាជធានី និងនៅតាមបណ្តាខេត្តនានា ក្នុងទូទាំងប្រទេសដោយមិនត្រូវបានគិតថ្លៃនោះឡើយ ។




លោកអះអាងទៀតថាសម្រាប់ការទៅពិនិត្យ និងព្យាបាលជំងឺនេះ គឺពិតជាមានលក្ខណៈងាយស្រួលដោយបងប្អូនកម្មករកម្មការិនី គ្រាន់តែកាន់ប័ណ្ណសមាជិក ប.ស.ស ទៅជាមួយនោះភ្នាក់ងារ ប.ស.ស ប្រចាំការនៅតាមមន្ទីរពេទ្យ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាពនឹងធ្វើការសម្របសម្រួលជូន។

សូមបញ្ជាក់ថា៖ **សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ (TYDA)** បង្កើតឡើងនៅថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១២ ក្រោមការផ្តួចផ្តើមគំនិតផ្ទាល់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត** និង **លោកជំទាវវេជ្ជបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** ក្នុងគោលបំណង ដើម្បីផ្តល់សេវាព្យាបាល ដល់ប្រជាពលរដ្ឋក្រីក្រនានាទូទាំងប្រទេសកម្ពុជាដោយមិនប្រកាន់និន្នាការនយោបាយនោះឡើយ៕

# មន្ត្រី ប.ស.ស សាខាខេត្តប៉ៃលិន ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ ដល់កម្មករនិយោជិត នៅក្រុមហ៊ុន វិចតូរីយ៉ាវ៉ាយអ៊ីន





**ប៉ៃលិន៖** ក្រុមការងារ ប.ស.ស សាខាខេត្តប៉ៃលិន ដឹកនាំដោយ លោក **រាម សុមិត្រ** មន្ត្រីទទួលបន្ទុកខេត្ត បានចុះធ្វើបទបង្ហាញស្តីពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម កាលពីថ្ងៃព្រហស្បតិ៍ ១០កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨ ជូនដល់តំណាងក្រុមហ៊ុន និងកម្មករនិយោជិតនៅ ក្រុមហ៊ុន វិចតូរីយ៉ាវ៉ាយអ៊ីន ស្ថិតនៅភូមិផ្សារព្រំ សង្កាត់ស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន។

ជាកិច្ចចាប់ផ្តើម លោក **លី ចាន់ថន** តំណាងរដ្ឋបាលក្រុមហ៊ុន បានលើកឡើងថា លោកពិតជាស្វាគមន៍ចំពោះក្រុមការងារ បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានចុះមកផ្សព្វផ្សាយពីអត្ថប្រយោជន៍របបសន្តិសុខសង្គម ដល់កម្មករនិយោជិត នៅក្នុងក្រុមហ៊ុន វិចតូរីយ៉ាវ៉ាយអ៊ីន កាន់តែមានការយល់ដឹងច្បាស់ពីអត្ថប្រយោជន៍របបសន្តិសុខសង្គម។

លោកបានបន្តថា នាពេលកន្លងមក មានបុគ្គលិកក្រុមហ៊ុនជាច្រើននាក់ បានទទួលរងគ្រោះថ្នាក់ការងារ និងបានទៅទទួលសេវាផ្នែកថែទាំសុខភាព ត្រូវបានក្រុមការងារ ប.ស.ស រួមទាំងភ្នាក់ងារប្រចាំការមន្ទីរពេទ្យ ជួយធ្វើការសម្របសម្រួលជូនជាបន្តបន្ទាប់។

ជាកិច្ចបន្ត លោក **រាម សុមិត្រ** មន្ត្រីទទួលបន្ទុកខេត្ត បានបញ្ជាក់ថាទាក់ទង និងស្ថានភាពសុខភាពនេះថា បងប្អូនកម្មករនិយោជិតនឹងទទួលបានការពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃ នៅតាមមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស។ ពិសេសបងប្អូនកម្មករនិយោជិតនឹងទទួលបានប្រាក់បំណាច់ ប្រចាំថ្ងៃ ៧០% នៃប្រាក់ឈ្នួលមធ្យមជាប់ភាគទាន សម្រាប់រយៈពេលអាក់ខានការងារ ដោយសារការសម្រាកព្យាបាលថែទាំជំងឺ ឬរបួសតាមវេជ្ជបញ្ជាមានរយៈពេល ជាប់គ្នាលើសពី ០៧ថ្ងៃ ដោយរាប់ចាប់ពីថ្ងៃទី១ដែលកម្មករនិយោជិតបានចូលទៅមូលដ្ឋានសុខាភិបាល។

លោកបានបញ្ជាក់ថា នេះបើយោងតាមប្រកាសលេខ ១៨៤ ក.ប/ប្រ.ក ប.ស.ស ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលប្រការ២ ប្រការ៤ ប្រការ៥ ប្រការ៦ ប្រការ៧ ប្រការ៨ និងប្រការ១០ នៃប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីតាវកាលិកថែទាំសុខភាព។

**សម្តេចតេជោ** នាយករដ្ឋមន្ត្រីក៏បានលើកឡើងផងដែរថា នៅពាក់កណ្តាលឆ្នាំ ២០១៩ នេះយើងបានសិក្សា ហើយប្រកាសចេញជាក្របខណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាល និងមានការអនុវត្តចំពោះស្ត្រីក្រីក្រ ដែលមានផ្ទៃពោះ និងឆ្លងទន្លេ ដោយទទួលបានថវិកាពីរាជរដ្ឋាភិបាលរហូតដល់ ៧៦០ ០០០រៀល វាច្រើនជាងកម្មការិនី ដែលបានតែ ៤០០ ០០០រៀល និងសុំទោសចំពោះស្ត្រីនៅទូទាំងប្រទេស ដែលថវិកានេះមិនអាចផ្តល់ឱ្យគ្រប់គ្នាបានទេ ព្រោះសមធម៌មិនគួរត្រូវបានអនុវត្តសម្រាប់គ្រប់គ្នានោះទេ ដោយសារថា អ្នកក្រីក្រ គួរតែទទួលបានការជួយពីរាជរដ្ឋាភិបាលទើបជាសមធម៌សង្គម ៕

# សកម្មភាពក្រុមការងារ ប.ស.ស ចុះប្រគល់សម្ភារៈ អវយវៈសិប្បនិមិត្ត និងធ្វើបច្ចុប្បន្នភាពជូនសមាជិក ប.ស.ស

**កណ្តាល៖** កាលពីថ្ងៃពុធ ០១កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៣ ខែមិថុនា ឆ្នាំ ២០១៨ ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះផ្តល់រទេះរុញ ព្រមទាំងបង្រៀនពីរបៀបប្រើប្រាស់ និងពិនិត្យពីស្ថានភាពរស់នៅជាក់ស្តែងដល់សមាជិក ប.ស.ស ដែលទទួលរងគ្រោះថ្នាក់ការងារ។

ការចុះផ្តល់នេះ គឺដើម្បីធានាឱ្យបាន ក្នុងការផ្តល់សេវាស្តារនីតិសម្បទាបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពជាពិសេសគឺ ជួយសម្របសម្រួលដល់ជនរងគ្រោះដែលជាជនពិការ ដោយគ្រោះថ្នាក់ការងារ តាមរយៈការជួយដោះស្រាយបញ្ហាតាមគោលការណ៍ដល់លំនៅឋានផ្ទាល់របស់ពួកគាត់ ព្រមទាំងលើកទឹកចិត្តតាមមធ្យោបាយផ្សេងៗ ដោយពន្យល់ពួកគាត់ក៏ដូចជាសាច់ញាតិឱ្យបានយល់ដឹងកាន់តែច្បាស់អំពីអត្ថប្រយោជន៍របបសន្តិសុខសង្គម៕



**កំពង់ធំ៖** ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីថ្ងៃព្រហស្បតិ៍ ០២កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ បានចុះ ផ្តល់រទេះរុញព្រមទាំងបង្រៀនពីរបៀបប្រើប្រាស់ និង ពិនិត្យពីស្ថានភាពរស់នៅជាក់ស្តែងដល់សមាជិក ប.ស.ស ដែលទទួលរងគ្រោះថ្នាក់ការងារ៕



**ស្វាយរៀង៖** កាលពីថ្ងៃចន្ទ័ ៦រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១៨ ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះធ្វើបច្ចុប្បន្នភាពសមាជិកពិការភាព តាមដានការផ្តល់ សេវានិងពន្យល់នីតិវិធីនៃការផ្តល់សេវាស្តារនីតិសម្បទា ដើម្បីការពារអត្ថប្រយោជន៍ផ្សេងៗរបស់កម្មករនិយោជិតជាសមាជិក ប.ស.ស៕



**ព្រៃវែង៖** កាលពីថ្ងៃច័ន្ទ ១៣រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចាត់តាំងថ្នាក់ដឹកនាំ និងបុគ្គលិក នៃការិយាល័យស្តារនីតិសម្បទា និងមានការសហការពីអ្នកជំនាញ Exceed Clinic ដើម្បីចុះពិនិត្យស្ថានភាពរបួស និងផ្តល់រទេះសម្រាប់ជនពិការ ដល់សមាជិក ប.ស.ស ស្ថិតនៅឃុំដូនកឹង និងឃុំស្មោងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង៕



**ស្ទឹងត្រែង៖**ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីថ្ងៃពុធ ២កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ បានចុះផ្តល់ឧបករណ៍ឈើច្រត់ និងអត្ថប្រយោជន៍ផ្សេងៗ ដែល ប.ស.ស ផ្តល់ជូនដល់សមាជិកស្ថិតនៅភូមិបាចុង សង្កាត់ព្រះបាទ ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង៕



**កោះកុង-កំពង់ស្ពឺ៖** កាលពីថ្ងៃច័ន្ទ ៧កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨ ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចាត់មន្ត្រី និងបុគ្គលិក នៃការិយាល័យស្តារនីតិសម្បទា ព្រមទាំងសាខា ខេត្តកោះកុង និងសាខាខេត្តកំពង់ស្ពឺ ចុះពិនិត្យស្ថានភាពរបួស និងតាមដានការផ្តល់សេវាស្តារនីតិសម្បទាដល់សមាជិក ប.ស.ស៕



**សៀមរាប-ឧត្តរមានជ័យ៖** នាថ្ងៃពុធ ២កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៦ ខែឧសភា ឆ្នាំ ២០១៨ មន្ត្រីជំនាញការិយាល័យស្តារនីតិសម្បទា នៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះទៅធ្វើបច្ចុប្បន្នភាពឱ្យ សមាជិក ប.ស.ស ដែលទទួលរងពិការភាពតាមដានការផ្តល់សេវាស្តារនីតិសម្បទា និងពន្យល់ណែនាំអំពីនីតិវិធី នៃការផ្តល់សេវាស្តារនីតិសម្បទា ដល់សាខា ប.ស.ស ខេត្តសៀមរាប-ខេត្តឧត្តរមានជ័យ។



ចាប់ពីថ្ងៃចន្ទ ទី០៧ រហូតដល់ថ្ងៃពុធ ទី០៩ ខែឧសភា ឆ្នាំ២០១៨ មន្ត្រីជំនាញការិយាល័យស្តារនីតិសម្បទា នៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះទៅធ្វើបច្ចុប្បន្នភាពឱ្យ សមាជិក ប.ស.ស ដែលទទួលរងពិការភាព តាមដានការផ្តល់សេវាស្តារ និងពន្យល់ណែនាំអំពីនីតិវិធីនៃការផ្តល់សេវាស្តារនីតិសម្បទាដល់សាខា ប.ស.ស ខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី និងខេត្តមណ្ឌលគិរី៕

# ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកចុះបណ្តុះបណ្តាល ច្បាប់ចរាចរណ៍ផ្លូវគោកដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិត

**ខេត្តកណ្តាល៖** កាលពីថ្ងៃអង្គារ ៨កើត និងថ្ងៃពុធ ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី២២ និង២៣ ខែឧសភា ឆ្នាំ២០១៨ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកនៃបេឡាជាតិរបបសន្តិសុខសង្គម បានចុះបណ្តុះបណ្តាលស្តីពីច្បាប់ចរាចរណ៍ដល់អ្នកបើកបរយានយន្តដឹងកម្មករនិយោជិតនៅរោងចក្រ TY FASHION (CAMBODIA ) CO.,LTD មានចំនួន៤១នាក់ និងរោងចក្រ UNITY FASHION CAMBO CO., LTD មានចំនួន១៥នាក់ ស្ថិតនៅស្រុកពញាឮ ខេត្តកណ្តាល។



វគ្គបណ្តុះបណ្តាលនេះធ្វើឡើងក្នុងគោលបំណងដើម្បីបញ្ជ្រាបចំណេះដឹងអំពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់អ្នកបើកបរ និងជម្រុញឱ្យមានការចូលរួមគោរពច្បាប់ចរាចរណ៍ផ្លូវគោកឱ្យបានត្រឹមត្រូវ ក្នុងន័យរួមចំណែកកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ឱ្យមកនៅកម្រិតទាប៕

**ខេត្តកណ្តាល៖** ការធ្វេសប្រហែសណាមួយ ឬមិនគោរពច្បាប់ចរាចរណ៍អាចបណ្តាលឱ្យមានគ្រោះថ្នាក់ណាមួយជាក់ជាមិនខាន ដូចនេះដើម្បីរួមចំណែកកាត់បន្ថយគ្រោះថ្នាក់ ចរាចរណ៍ កាលពីថ្ងៃអង្គារ ១៥កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកនៃបេឡាជាតិរបបសន្តិសុខសង្គម បានចុះបណ្តុះបណ្តាលស្តីពីច្បាប់ចរាចរណ៍ដល់អ្នកបើកបរយានយន្តដឹកកម្មករ និយោជិតនៅរោងចក្រ ០៣រួម មាន៖

១.រោងចក្រ SKYLINE APPAREL CO.,LTD ស្ថិតនៅ ស្រុកកៀនស្វាយ ខេត្តកណ្តាល មានអ្នកចូលរួម ចំនួន ១៦នាក់។



២. រោងចក្រ SIXPLUS INDUSTRY CO.,LTD ស្ថិតនៅស្រុកមុខកំពូល ខេត្តកណ្តាល មានអ្នកចូលរួមចំនួន ២៧នាក់។

៣. រោងចក្រ NOW CORP CO.,LTD ស្ថិតនៅស្រុកអង្គស្នួល ខេត្តកណ្តាល មានអ្នកចូលរួម ១៨នាក់៕

**ខេត្តកំពង់ចាម៖** ដើម្បីរួមចំណែកកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ជារៀងរាល់ថ្ងៃ នៅថ្ងៃព្រហស្បតិ៍ ១១រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកនៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានចុះបណ្តុះបណ្តាលអប់រំផ្សព្វផ្សាយ ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោកដល់អ្នកបើកបរយាន យ ន្តដឹក កម្មករនិយោជិតចំនួន១២៧នាក់នៅរោងចក្រ CARLINGTON (CAMBODIA) CO., LTD ស្ថិតនៅស្រុកជើងព្រៃ ខេត្តកំពង់ចាម៕



**ខេត្តកំពង់ចាម៖** ដោយមើលឃើញអំពីស្ថានភាពគ្រោះថ្នាក់ចរាចរណ៍ជារៀងរាល់ថ្ងៃ បណ្ដាលមកពីអ្នកបើកបរមួយចំនួនមិនសូវគោរពច្បាប់ចរាចរណ៍ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានចុះបណ្ដុះបណ្ដាលអប់រំផ្សព្វផ្សាយស្ដីពីច្បាប់ចរាចរណ៍ផ្លូវគោកដល់អ្នកបើកបរយានយន្តដឹកកម្មករ និយោជិតចំនួន ៥៩នាក់ នៅរោងចក្រ JUHUI FOWEAR CO., LTD ស្ថិតនៅស្រុកជើងព្រៃ ខេត្តកំពង់ចាម កាលពីថ្ងៃអង្គារ ៨កើត ខែពិសាខឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨។



**ខេត្តកំពង់ឆ្នាំង៖** ជារៀងរាល់ថ្ងៃមានមនុស្សមួយចំនួនតូចផ្ដើមចេញពីអ្នកបើកបរមិនគោរពច្បាប់ចរាចរណ៍ឱ្យបានខ្ជាប់ខ្ជួន ដោយមានការធ្វេសប្រហែស ការបើកបរលើសល្បឿនកំណត់ បើកបរក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ទើបក្រុមការងាសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៃបេឡាជាតិរបបសន្តិសុខសង្គម បានចុះបណ្ដុះបណ្ដាលអប់រំផ្សព្វផ្សាយស្ដីពីច្បាប់ច រាច រ ណ៍ផ្លូវគោកដល់អ្នកបើកបរយានយន្តដឹកកម្មករ និយោជិតចំនួន៥៣នាក់ នៅរោងចក្រ Tripos International (Cambodia) Co., Ltd ស្ថិតនៅខេត្តកំពង់ឆ្នាំង កាលពីថ្ងៃចន្ទ ១៤កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨។



**ខេត្តកំពង់ឆ្នាំង៖** កាលពីថ្ងៃព្រហស្បតិ៍ ៩កើត ខែបឋមា-សាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែ មិថុនា ឆ្នាំ២០១៨ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៃបេឡាជាតិរបបសន្តិសុខសង្គម បានចុះបណ្ដុះបណ្ដាលច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោកដល់អ្នកបើកបរយានយន្តដឹកកម្មករ និយោជិតនៅរោងចក្រ M&V International Manufacturing CO,LTD ចំនួន ២០នាក់ ដើម្បីត្រៀមប្រឡងផ្ដល់បណ្ណបើកបរ ឱ្យស្របតាមប្រភេទយានដែលច្បាប់បានកំណត់ ស្ថិតនៅខេត្តកំពង់ឆ្នាំង។




**ខេត្តកំពង់ស្ពឺ៖** កាលពីថ្ងៃអាទិត្យ ៦កើត ខែជេស្ឋ ឆ្នាំច នព្វស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៨ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៃបេឡាជាតិរបបសន្តិសុខសង្គម បានចុះបណ្ដុះបណ្ដាលអប់រំផ្សព្វផ្សាយ ស្ដីពីច្បាប់ចរាចរណ៍ផ្លូវគោកដល់អ្នកបើកបរយានយន្តដឹកកម្មករ និយោជិតចំនួន ៤៦នាក់ នៅសាលាស្រុកគងពិសី ស្ថិតនៅខេត្តកំពង់ស្ពឺ។



**ខេត្តកំពង់ស្ពឺ៖** កាលពីថ្ងៃពុធ ១កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១៣ ខែមិថុនា ឆ្នាំ ២០១៨ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកនៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានចុះបណ្ដុះបណ្ដាលច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោកដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិត នៅរោងចក្រ **WING STAR SHIES** ចំនួន ៦៥នាក់ នៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ៕



**ខេត្តព្រះសីហនុ៖** កាលពីថ្ងៃពុធ ៩កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០១៨ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៃបេឡាជាតិរបបសន្តិសុខសង្គម បានចុះបណ្ដុះបណ្ដាល និងផ្សព្វផ្សាយច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ជូនដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិត នៅស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេស ក្រុងព្រះសីហនុ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដោយមានអ្នកចូលរួមចំនួន ៦៥នាក់៕



**ខេត្តព្រះសីហនុ៖** ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) កាលពីថ្ងៃ ពុធ ៨កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃ ទី២០ ខែមិថុនា ឆ្នាំ២០១៨ បានចុះបណ្ដុះបណ្ដាលច្បាប់ស្ដីពីចរាចរណ៍ផ្លូវ គោក អ្នកបើកបរយានយន្តដឹកកម្មករនិយោជិតនៅរោងចក្រ **Men Ou Garment Co.,Ltd** ចំនួន ១៩នាក់៕



**ខេត្តតាកែវ៖** ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៃបេឡាជាតិរបបសន្តិសុខសង្គម កាលពីថ្ងៃសុក្រ ៤កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៨ ខែឧសភា ឆ្នាំ ២០១៨ បានចុះបណ្ដុះបណ្ដាលច្បាប់ចរាចរណ៍ផ្លូវគោក និងចែកប័ណ្ណមូលនិធិសមធម៌សុខាភិបាលនៅរោងចក្រ **Pontus Footwear Ltd** ខេត្តតាកែវ ដោយមានអ្នកចូលរួមចំនួន ១៥នាក់៕



**ខេត្តតាកែវ៖** កាលពីថ្ងៃព្រហស្បតិ៍ ២កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ២០១៨ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានចុះបណ្ដុះបណ្ដាលច្បាប់ចរាចរណ៍ផ្លូវគោកដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិតនៅរោងចក្រ **Beautiful Spring Footwear Co., Ltd** នៅខេត្តតាកែវ ដោយមានអ្នកចូលរួមចំនួន ៥១នាក់៕



**រាជធានីភ្នំពេញ៖** ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) កាលពីថ្ងៃចន្ទ ៦រោច ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី០៤ ខែ មិថុនា ឆ្នាំ២០១៨ បានចុះទៅបណ្តុះបណ្តាលច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិតនៅរោងចក្រ **MOHA GARMENT CO.,LTD** ស្ថិតក្នុងខណ្ឌដង្កោ រាជធានីភ្នំពេញ ដោយមានអ្នកចូលរួម ចំនួន ៦០នាក់៕



**ស្វាយរៀង៖** ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកនៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានសហការជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណការ និងដឹកជញ្ជូន កាលពីថ្ងៃពុធ ៩កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ បានចុះបណ្តុះបណ្តាល និងផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកជូនដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិតដឹកកម្មករនិយោជិត នៅរោងចក្រចក្រ **LU THAI (Cambodia) CO., LTD** ស្ថិតនៅ ខេត្តស្វាយរៀង ដោយមានអ្នកចូលរួមចំនួន ២៣នាក់៕



**រាជធានីភ្នំពេញ៖** ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកនៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) កាលពីថ្ងៃ សៅរ៍ ៣រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ បានចុះទៅបណ្តុះបណ្តាលច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដល់អ្នកបើកបរយានយន្តដឹកកម្មករ និយោជិត នៅរោងចក្រ **Cambo Handsome Co.., LTD** ស្ថិតនៅខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដោយមានអ្នកចូលរួមចំនួន ៦៥នាក់៕



**ស្វាយរៀង៖** កាលពីថ្ងៃសុក្រ ១០រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៨ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកនៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានសហការជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណការ និងដឹកជញ្ជូន និងសហភាព សហព័ន្ធយុវជនកម្ពុជាខេត្តស្វាយរៀង បានចុះបណ្តុះបណ្តាលច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិតនៅរោងចក្រ **TOWA (Cambodia) Co.,Ltd** ស្ថិត នៅក្រុងបាវិត ខេត្តស្វាយរៀង ដោយមានអ្នកចូលរួមចំនួន ៤៥នាក់៕





**ពោធិ៍សាត់៖** ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) កាលពីថ្ងៃពុធ ១កើត ខែ បឋម សាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៣ ខែ មិថុនា ឆ្នាំ២០១៨ បានចុះទៅបណ្តុះបណ្តាលច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិត ស្ថិតនៅសាលាស្រុកក្រគរ ខេត្តពោធិ៍សាត់ ដោយ មានអ្នកចូលរួម ៣៧នាក់។



**ព្រៃវែង៖** កាលពីថ្ងៃពុធ ០១កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានចុះទៅបណ្តុះបណ្តាលច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិត នៅរោងចក្រ ORANGE MANUFACTURING (KHMER) CO.,LTD ស្ថិតនៅស្រុកកំចាយមារ ខេត្តព្រៃវែង ដោយមានអ្នកចូលរួមចំនួន ១៥នាក់។





# សកម្មភាពក្រុមការងារចុះកំណត់អត្តសញ្ញាណ កម្មករ កម្មការិនី

**ត្បូងឃ្មុំ៖** ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សាខាខេត្តត្បូងឃ្មុំ កាលពីថ្ងៃចន្ទ ០៦រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ បានចុះកំណត់អត្តសញ្ញាណ កម្មករ កម្មការិនី និយោជិតតាម (Online) នៅរោងចក្រកាត់ដេរថប់ស៊ុលវើ ២ និងក្រុមហ៊ុនឡុងស្រេងអ៊ិនធើណេតស៊ិនណលបានចំនួន ៤០នាក់។ ការចុះកំណត់អត្តសញ្ញាណគឺដើម្បីឱ្យកម្មករ កម្មការិនីទទួលបានអត្ថប្រយោជន៍ផ្សេងៗដែល ប.ស.ស ផ្តល់ជូន៕



**ប៉ៃលិន៖** កាលពីថ្ងៃអង្គារ ០៧រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨ ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សាខាខេត្តប៉ៃលិន បានចុះកំណត់អត្តសញ្ញាណនៅក្រុមហ៊ុនក្រោនវិចតូរីយ៉ា និងសណ្ឋាគារពិទូរ្យប៉ៃលិន ដែលមានទីតាំងស្ថិតនៅភូមិផ្សារព្រំ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន។ គោលបំណងនៃការកំណត់អត្តសញ្ញាណ គឺដើម្បីឱ្យបុគ្គលិកមានសិទ្ធិទៅ ប្រើប្រាស់របបសន្តិសុខសង្គមហានិភ័យការងារ និងទទួលសេវាថែទាំសុខភាព នៅតាមមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ដោយឥតបង់ថ្លៃ៕



**មណ្ឌលគិរី៖** ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសាខាខេត្តមណ្ឌលគិរី កាលពីថ្ងៃអង្គារ ០៧រោច ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨។ បាន ចុះកំណត់អត្តសញ្ញាណជូនកម្មករនិយោជិតតាមប្រព័ន្ធ Offline នៅក្រុមហ៊ុនកៅស៊ូ ប៊ិញហ្វឿកក្រចេះវ៉ាប់ប័រ១ ដែលមានទីតាំងស្ថិតនៅភូមិពូគង់ ឃុំស្រែព្រះកែវសីមា ខេត្តមណ្ឌលគិរី សរុបចំនួន ១៥១នាក់។



ការចុះកំណត់អត្តសញ្ញាណគឺដើម្បីឱ្យគ្រប់កម្មករនិយោជិតមានសិទ្ធិទទួលបានសេវាធានារ៉ាប់រងរបបសន្តិសុខសង្គម (ប.ស.ស) ផ្នែកហានិភ័យការងារ (គ្រោះថ្នាក់ការងារ) ផ្នែកថែទាំសុខភាព ដែលពួកគាត់ទាំងអស់អាចទៅពិនិត្យ និងព្យាបាលជំងឺ នៅគ្រប់មន្ទីរពេទ្យដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ដោយឥតបង់ប្រាក់៕

**ព្រះវិហារ៖** ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សាខាខេត្តព្រះវិហារ បានចុះកំណត់អត្តសញ្ញាណជូនកម្មករ កម្មការិនីនិយោជិត កំពុងបម្រើការនៅក្រុមហ៊ុនទ្រីភាព ស្ថិតនៅភូមិជី អោក ឃុំរមណីយ ស្រុករវៀង ខេត្តព្រះវិហារ កាលពីថ្ងៃពុធ ០៨រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៨៕





**ព្រៃវែង៖** ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សាខាខេត្តព្រៃវែង បាន ចុះកំណត់អត្តសញ្ញាណ ជូនកម្មករនិយោជិត ដែលបម្រើការ នៅក្រុមហ៊ុន អរិន មេនូហ្វេកធីរីង (ខ្មែរ) តាមប្រព័ន្ធ Offline បាន ចំនួន ១០៦នាក់ ស្ថិតនៅស្រុកកំចាយមារ ខេត្តព្រៃវែង កាលពី ថ្ងៃព្រហស្បតិ៍ ៩រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវ នឹងថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០១៨៕

**កំពង់ឆ្នាំង៖** ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សាខា ខេត្តកំពង់ឆ្នាំង បានចុះកំណត់អត្តសញ្ញាណបុគ្គលិកដែលបម្រើ ការងារនៅរោងចក្រហ្សាណាតិច (ខេមបូឌា) ស្ថានីយ៍ប្រេង ឥន្ធនៈសែប និងត្រពាំងឫស្សី KTVចំនួន ១៦៥នាក់ ស្ថិតនៅ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃថ្ងៃអង្គារ ១៤រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិ ស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែមិថុនា ឆ្នាំ ២០១៨៕



**តាកែវ៖** ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សាខាខេត្តតាកែវ បានចុះកំណត់អត្តសញ្ញាណបុគ្គលិកដែល បម្រើការងារនៅកាស៊ីណូតាកែវ ដែលមានទីតាំងស្ថិតនៅ ខេត្តតាកែវ កាលពីថ្ងៃសុក្រ ១០រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៨៕



ចាប់ពីថ្ងៃចន្ទ ទី០៧ រហូតដល់ថ្ងៃពុធ ទី០៩ ខែឧសភា ឆ្នាំ២០១៨ មន្ត្រីជំនាញការិយាល័យស្តារនីតិសម្បទា នៃ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះទៅធ្វើបច្ចុប្បន្នភាព ឱ្យ សមាជិក ប.ស.ស ដែលទទួលរងពិការភាព តាមដានការផ្តល់ សេវាស្តារនិងពន្យល់ណែនាំអំពីនីតិវិធីនៃការផ្តល់សេវាស្តារនី តិសម្បទា ដល់សាខា ប.ស.ស ខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី និងខេត្តមណ្ឌលគិរី៕

# សកម្មភាពក្រុមការងារតាមបណ្តាខេត្ត ចុះបំពេញឯកសារ និងផ្តល់ថវិកាជូនស្ត្រីសម្រាលកូន

សកម្មភាពក្រុមការងារតាមបណ្តាខេត្តចុះបំពេញឯកសារ និងផ្តល់ថវិកាជូនស្ត្រីសម្រាលកូនដោយអនុលោមតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ នឹងឧបត្ថម្ភគោលរបបជាសាច់ប្រាក់សុទ្ធ ដល់កម្មករនិយោជិតជាស្ត្រីទាំងក្នុង និងក្រៅប្រព័ន្ធ ដែលបានចុះបញ្ជីជាមួយ ប.ស.ស សម្រាប់ស្ត្រីនៅពេលសម្រាលបានកូន ១នាក់ នឹងទទួលបានថវិកាឧបត្ថម្ភចំនួន ៤០ម៉ឺនរៀល សម្រាលបានកូនភ្លោះ ២នាក់ ទទួលបានថវិកាឧបត្ថម្ភចំនួន ៨០ម៉ឺនរៀល សម្រាលបានកូនភ្លោះ ៣នាក់ ទទួលបានថវិកាឧបត្ថម្ភចំនួន ១លាន ២០ម៉ឺនរៀល ជាងនេះទៅទៀតកូនភ្លោះ៣ នឹងទទួលបានថវិកាឧបត្ថម្ភបន្ថែមចំនួន ៥លានរៀលពី **សម្តេចតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** បើទោះបីសម្រាលមកកូននោះស្លាប់ក៏ដោយក៏ទទួលបានថវិកាឧបត្ថម្ភបន្ថែមនេះដែរ។

**ព្រៃវែង៖** កាលពីថ្ងៃអង្គារ ១៤រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៨ ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សាខាខេត្តព្រៃវែងបានចុះសួរសុខទុក្ខ និងបំពេញទម្រង់លិខិតស្នើសុំប្រាក់ឧបត្ថម្ភបន្ថែមចំនួន ៤០ម៉ឺនរៀល ជូនស្ត្រីសម្រាលកូន ០១នាក់ កាលពីព្រឹកថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨។



**កំពង់ចាម៖** ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សាខាកំពង់ចាម កាលពីថ្ងៃពុធ ០១កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨បានចុះសួរសុខទុក្ខ និងបានសម្របសម្រួលរៀបចំឯកសារដើម្បីបើកប្រាក់ឧបត្ថម្ភបន្ថែមដល់កម្មការិនី ០២នាក់ ដោយម្នាក់ៗទទួលបានថវិកា ៤០ម៉ឺនរៀល។



**កំពង់ឆ្នាំង៖** នៅថ្ងៃព្រហស្បតិ៍ ៩រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សាខាខេត្តកំពង់ឆ្នាំងបានចុះពន្យល់ពីនីតិវិធីផ្តល់សេវាព្យាបាលដល់មន្ត្រី រាជការសាធារណៈ អតីតយុទ្ធជន និងនីតិវិធីទូទាត់ថ្លៃព្យាបាល ដល់មន្ត្រី បុគ្គលិកសុខាភិបាល ដែលបម្រើការនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈនៅខេត្តកំពង់ឆ្នាំង ព្រមទាំងបានចុះ សួរសុខទុក្ខ និងបំពេញទម្រង់លិខិតស្នើសុំប្រាក់ឧបត្ថម្ភបន្ថែម ៤០ម៉ឺនរៀល ជូនស្ត្រីសម្រាលកូន ០១នាក់។



**ត្បូងឃ្មុំ៖** ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សាខាខេត្តត្បូងឃ្មុំ នៅថ្ងៃព្រហស្បតិ៍ ៩ រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៧ ខែមិថុនា ឆ្នាំ ២០១៨បានចុះសួរសុខទុក្ខកម្មការិនី និងសម្របសម្រួលរៀបចំឯកសារដើម្បីបើកប្រាក់ឧបត្ថម្ភបន្ថែមដល់កម្មការិនី ០២នាក់ ដោយម្នាក់ៗទទួលបានថវិកា៤០ម៉ឺនរៀល។



**ប៉ៃលិន៖** កាលពីថ្ងៃអង្គារ ១៤ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០១៨ ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សាខាខេត្តប៉ៃលិន បានចុះសួរសុខទុក្ខ និងសម្របសម្រួលរៀបចំឯកសារជូនដល់កម្មការិនីដែលសម្រាលកូនចំនួន ០១នាក់ នៅមន្ទីរពេទ្យបង្អែកខេត្តប៉ៃលិន ដើម្បីបើកប្រាក់ឧបត្ថម្ភបន្ថែម ៤០ម៉ឺនរៀល។



**សៀមរាប៖** ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សាខាខេត្តសៀមរាប កាលពីថ្ងៃពុធ ១៥ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០១៨ បានចុះសួរសុខទុក្ខ និងសម្របសម្រួលរៀបចំឯកសារជូនដល់កម្មការិនីដែលសម្រាលកូន ០៤នាក់ ដើម្បីទទួលបានប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាល ដោយម្នាក់ៗទទួលបានថវិកាចំនួន ៤០ម៉ឺនរៀល និងអត្ថប្រយោជន៍ផ្សេងៗជាច្រើនទៀត។



**មណ្ឌលគិរី៖** កាលពីថ្ងៃសុក្រ២រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០១៨ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សាខាខេត្តមណ្ឌលគិរី បានចុះសួរសុខទុក្ខ និងសម្របសម្រួលរៀបចំឯកសារជូនដល់កម្មការិនីដែលសម្រាលកូនចំនួន ០២នាក់ ដើម្បីទទួលបានប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាល ដោយម្នាក់ៗទទួលបានថវិកាចំនួន ៤០ម៉ឺនរៀល និងអត្ថប្រយោជន៍ផ្សេងៗ ជាច្រើនទៀត។



# កម្មករនិយោជិត ២រូប បានស្លាប់ និងម្នាក់រងរបួសធ្ងន់ ក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ នៅខេត្តព្រះសីហនុ

**ព្រះសីហនុ៖** ហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ដែលគួររន្ធត់មួយបានកើតឡើងកាលពីវេលាម៉ោង៦ និង ៤០នាទីព្រឹកថ្ងៃព្រហស្បតិ៍ ១១រោច ខែពិសាខ សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ កន្លងមកនេះ ដែលបង្កឡើងដោយរថយន្តដឹកសំរាមមួយគ្រឿងបានរេចង្កូតទៅបុកម៉ូតូម៉ាកហុងដាពណ៌ខ្មៅ ០១គ្រឿង បើកបរក្នុងទិសដៅស្របគ្នាពីក្រោយយ៉ាងពេញទំហឹងបណ្តាលឱ្យមនុស្ស ០២នាក់ស្លាប់បាត់បង់ជីវិតភ្លាមៗនៅនឹងកន្លែងកើតហេតុ និងរងរបួសធ្ងន់ម្នាក់ នៅលើកំណាត់ផ្លូវជាតិលេខ៤ ត្រង់ចំណុចបង្គោលគីឡូ២០៥ និង២០៦។



ជនរងគ្រោះឈ្មោះ **នេន ទិដ្ឋា** ភេទប្រុស អាយុ២១ឆ្នាំ មាន ទីលំនៅខេត្តកំព ត បាន ស្លាប់នៅក ន្លែង កើត ហេតុភ្លាមៗ តែម្តង។

រីឯជនរងគ្រោះម្នាក់ទៀតឈ្មោះ **ម៉ី ទិចិត្រ** ភេទប្រុស អាយុ ២១ឆ្នាំ ស្នាក់នៅភូមិបត់គគីរ ឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ បានស្លាប់នៅពេលបញ្ជូនដល់មន្ទីរពេទ្យបង្អែក ខេត្តព្រះសីហនុ ។



ចំណែកឯជនរងគ្រោះទី៣ មានឈ្មោះ **ម៉ៅ ទឹប** ភេទប្រុស អាយុ៣១ឆ្នាំ បានរងរបួសធ្ងន់ ហើយត្រូវបានបញ្ជូនទៅសម្រាកព្យាបាលនៅគ្លីនិចសេតេ ខេត្តព្រះសីហនុ។



ទាក់ទង និងកម្មករនិយោជិក ដែលរងគ្រោះថ្នាក់ក្នុងពេលទៅ និងមកពីបំពេញការងារ ក្រុមការងារ ប.ស.ស សាខាខេត្តព្រះសីហនុ បានសហការជាមួយកំលាំងសមត្ថកិច្ចមូលដ្ឋាន បានចុះទៅធ្វើការសម្របសម្រួល និងបញ្ជូនជនរងគ្រោះទៅសង្គ្រោះនៅមន្ទីរពេទ្យ រីឯជនរងគ្រោះដែលស្លាប់ត្រូវបានដឹកបញ្ជូនទៅឱ្យក្រុមគ្រួសារសពនៅស្រុកកំណើត ដើម្បីធ្វើបុណ្យតាមប្រពៃណី ។

សូមបញ្ជាក់ថា រាល់ថ្លៃសេវាដឹកជញ្ជូនអ្នករងគ្រោះ និងអ្នក ដែល បាន ស្លាប់ក្នុង ពេល គ្រោះថ្នាក់ការ ងារ នេះ ត្រូវ បាន ប.ស.ស ជាអ្នកទូទាត់សំណង ៕




**ព្រះតិរម្យភាសា អ៊ូ ហៅឌុំយ** កើតក្នុងឆ្នាំ១៨៦៥ នៅឃុំកំបូល
ស្រុកភ្នំពេញ(បច្ចុប្បន្នស្រុកអង្គស្នួល) ខេត្តកណ្ដាល។

# បណ្ដាំក្រមឌុំយ

ចង់ធំខំពីតូច    បើខ្លាចខូចកុំឆាប់ខឹង
ការធ្វើឱ្យចេះថ្លឹង    កុំប្រឹងចុះតាមដំរី។
កុំចង់ខ្ពស់ស្មើមេឃ    កុំឱនពេកអាប់រាសី
ទោះដើរនិយាយស្ដី    លៃឱ្យល្មមតែគួរសម។
យល់ឆ្ងាញកុំណាយគិត    ទោះយល់ជិតកុំអាលខំ
មិនជាក់មើលឱ្យចំ    ក្រែងប្រឡំសជាខ្មៅ។
ទម្លាប់ធំជាងច្បាប់    បើរៀនគ្រាប់កុំតាមខ្មៅ
គ្រាប់ប្រាជ្ញអាចប្រដៅ    ស្ដីកូនចៅឱ្យស្ដីឱ្យស្មោះ។

# វិធីថែសម្រស់ ១០ យ៉ាង ជាមួយនឹងក្រូចឆ្មារ

វិធីប្រើប្រាស់ក្រូច ឆ្មារដោយងាយៗខាង ក្រោមនឹងជួយឱ្យអ្នកកម្ចាត់ចោលការខ្វាយខ្វល់ព្រួយបារម្ភចំពោះភាពចំណាស់ ។



## ១.ការប្រើក្រូចឆ្មារដើម្បីថែទាំស្បែក

ចាប់ផ្តើមឈានចូលមជ្ឈិមវ័យ ស្បែកចាប់ផ្តើមមានស្នាមជ្រីវជ្រួញ ពិសេសស្បែកមុខកន្ទុយភ្នែក។ យកក្រូចឆ្មារប្រហែល១ផ្លែ ប្រសិនបើស្បែកឡើងប្រេងយក ១/៤ ចំណិត នោះបន្ថែមមួយចំហៀងទៀត តែបើស្បែកស្ងួតយកតែ ១/២ ចំណិត ដាក់ក្នុងចានធ្វើពីឈើ បន្ទាប់មកយកក្រែម (សម្រាប់ធ្វើនំ) កន្លះស្លាបព្រាបាយ និងទឹកដោះគោឆៅកន្លះចានចង្កឹះ កូរឱ្យសព្វដាក់ចូលក្នុងឆ្នាំងដាំឲ្យពុះរួចទុកឱ្យត្រជាក់។ យកដៃរបស់អ្នកជ្រលក់ចូលក្នុងសាធាតុនេះមកលាបលើផ្ទៃមុខ ម៉ាស្សាក្នុងរង្វង់ ២០នាទី ប្រសិនបើសារធាតុនោះវាគោកពេកអាចបន្ថែមប្រេងអូលីវ ២-៣ ដំណក់ចូល ម៉ាស្សា ២០នាទី រួចលាងទឹកចេញ ។

## ២.ក្រូចឆ្មារធ្វើឱ្យស្បែកភ្លឺ

យកក្រូចឆ្មារ ៣-៤ផ្លែ ច្របាច់ដាក់ក្នុងចានឈើ បន្ទាប់មកយកទឹកក្តៅឧណ្ហៗមកដាក់ចូលបន្ថែម ៤-៥ ស្លាបព្រាកាហ្វេ យកសំឡីមកជ្រលក់ ជូតលើមុខទុករយៈពេល ៣០នាទី អ្នកអាចធ្វើមួយថ្ងៃពីរទៅបីដង ប្រសិនបើចង់បានប្រសិទ្ធិភាពខ្ពស់។ វិធីនេះធ្វើសម្រាប់អ្នកមានស្បែកមុខស្រអាប់ និងឡើងជាំ។

## ៣.ក្រូចឆ្មារធ្វើឱ្យសក់រលោង

ចង់បានសក់រលើបរលោង ក្រោយពេលកក់សក់រួចម្តងៗ គប្បីយកទឹកក្រូចឆ្មារទៅកក់ ម្តងទៀតរួចសម្អាតដោយទឹក។

## ៤.ក្រូចឆ្មារ "កម្ចាត់សភាពស្បែកមានប្រេង និងមុនខ្សាច់"

ប្រសិនបើស្បែកអ្នកឡើងប្រេង នោះអ្នកនឹងប្រឈមការកើតមុនខ្សាច់ បែបនេះអ្នកគប្បី ប្រើទឹកក្រូចឆ្មារដោយយកសំឡីជ្រលក់ រួចជូតពីលើតំបន់ស្បែកដែលមានប្រេងច្រើន ក៏ដូចជាតំបន់ដែលរងការរាលដាលរបស់មុនខ្សាច់ ។ ព្រោះថាក្រូចឆ្មារវាមានសម ត្ថភាពធ្វើឱ្យរន្ធញើសរួមតូចមកវិញ ។

## ៥.បង្កើតលាងសម្អាតមុខពីក្រូចឆ្មារ

ក្នុងក្រូចឆ្មារមានផ្ទុក enzymes ម្យ៉ាងមានសមត្ថភាពសម្អាតស្បែក និងកម្ចាត់កោសិកាស្បែកដែលងាប់។ ហេតុនេះដោយពុំបាច់ចំណាយច្រើនក្នុងការ ទិញសារ ធាតុលាងសំអាតមុខអ្នកអាចប្រើក្រូចឆ្មារដើម្បីបង្កើតវា។ យកសាច់ជូរបន្តិច ដាក់ចូលជាមួយទឹកក្រូចឆ្មារមួយកំណាត់ រង់ចាំរហូតដល់ពេលសាច់ជូររលាយអស់ អ្នកយកសំឡីមកជ្រលក់ រួចតប់ៗលើស្បែកមុខ រួចរង់ចាំ ២០នាទី ចាំប្រើទឹកក្តៅឧណ្ហៗលាងសម្អាត។





## ៦.ក្រូចឆ្មារធ្វើឱ្យស្បែកម៉ដ្ឋរលោង

យកចេកណាំវ៉ាមួយផ្លែកិនឱ្យម៉ត់ លាយជាមួយទឹកក្រូចឆ្មារ បន្ទាប់មកយកមកលាបលើស្បែក ទុកពេល ២០ នាទី ទើបលាងចេញ។

## ៧.ក្រូចឆ្មារជួយកម្ចាត់អាចម៍រុយ

ដើម្បីទប់ស្កាត់ពេលឃើញសញ្ញាអាចម៍រុយលើស្បែក នោះអ្នកយកផ្នែកសនៃស៊ុតមួយគ្រាប់មកលាយទឹកក្រូចឆ្មារកន្លះស្លាបព្រា និងគ្រាប់អាល់ម៉ុង មួយគ្រាប់កិនម៉ត់ រួចលាយជាមួយស៊ុត និងទឹកក្រូចឆ្មារ មកលាបលើតំបន់ដែលមានអាចម៍រុយ លាបរាល់ថ្ងៃនឹងមានប្រសិទ្ធិភាព។



## ៨. ក្រូចឆ្មារជួយទប់ទល់ការជ្រុះសក់

យកទឹកក្រូចឆ្មារ ១ស្លាបព្រា លាយជាមួយប្រេងដូងមួយស្លាបព្រា កូរឱ្យសព្វលាបលើសក់ ទុកប្រមាណ ២០នាទី ទើបលាងទឹក។

## ៩.ក្រូចឆ្មារកម្ចាត់អង្គែ

យកទឹកក្រូចឆ្មារមកលាយជាមួយផ្នែកសនៃស៊ុតមាត់ ហើយលាបឲ្យសព្វពីគល់សក់ដល់ចុងសក់ឲ្យសើមជោគ ទុកប្រមាណ១ម៉ោង បន្ទាប់មកទើបលាងសំអាតនឹងទឹកត្រជាក់។



## ១០.ក្រូចឆ្មារថែទាំរាងកាយ

យកទឹកក្រូចឆ្មារលាយក្នុងបរិមាណស្មើគ្នាជាមួយទឹកប៉េងប៉ោះ (ប៉េងប៉ោះកៀបត្រងយកតែទឹក) ហើយយកកន្សែងមកជ្រលក់ជូតពេញដងខ្លួន ទុកមួយសន្ទុះប្រមាណពី ១០-២០នាទី ទើបងូតសម្អាតជាមួយទឹកក្ដៅឧណ្ហៗ ប្រសិនបើអាចអ្នកអាចធ្វើវារៀងរាល់ថ្ងៃ។

**ប្រភព:** http://www.cen.com.kh/

# ទំនាក់ទំនងតាមរយៈ


អាស័យដ្ឋានៈ អាគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទៈ (០២៣) ៨៨ ២៤ ៣៤ / ៩៩ ៨៤ ១៧

(០២៣) ៩៩ ៨៤ ១៨ / ៩៩ ៨៤ ១៩

គេហទំព័រៈ *www.nssf.gov.kh*

អ៊ីម៉ែលៈ *info@nssf.gov.kh*